វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

THE NGO FORUM ON CAMBODIA

# Fast-wood Plantations, Economic Concessions and Local Livelihoods in Cambodia

# ចំការឈើដាំឆាប់បានផល សម្បទានសេដ្ឋកិច្ច និងការចិញ្ចឹមជីវិតតាមមូលដ្ឋាន នៅប្រទេសកម្ពុជា

## Field Investigations in Koh Kong, Kampong Speu, Pursat, Kampong Chhnang, Mondolkiri, Prey Veng and Svay Rieng Provinces

Program on Rights and Justice (PRAJ)

កម្មវិធីសិទ្ធិ និង យុត្តិធម៌ (ប្រាជ្ញ)

# សង្ខេប

នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះគំរូអភិវឌ្ឍន៍បែប "សម្បទានសេដ្ឋកិច្ច" បានកើនយ៉ាងឆាប់រហ័សនៅលើផ្ទៃដីដ៏ធំធេងក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធ្វើចំការឈើដាំដែលមានទ្រង់ទ្រាយធំៗ។ ខណៈពេលដែលអ្នកគាំទ្រគំរោងចំការឈើដាំបានអះអាងថា គំរោងនេះនឹងផ្តល់ជាសារៈប្រយោជន៏យ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសំរាប់ប្រទេសកម្ពុជានោះ ក៏មានអ្នកប្រឆាំងអះអាងថា វានឹងមិនបានផ្តល់ផលប្រយោជន៏ដល់អ្នករស់នៅតាមជនបទឡើយ លើសពីនេះទៅទៀតគំរោងចំការឈើដាំដែលមានទ្រង់ទ្រាយធំៗបែបនេះនឹងផ្តល់ផលប៉ះពាល់ជាអវិជ្ជមានយ៉ាងច្រើនដល់សង្គម និងប្រពន្ឋ័បរិស្ថាន។ គំរូបែបសម្បទានសេដ្ឋកិច្ចជាច្រើនគឺក្នុងគោលបំណងជំរុញការអភិវឌ្ឍប្រទេសកម្ពុជា ដូចនេះវាជាការសំខាន់ណាស់ដែលត្រូវធ្វើការវាយតំលៃ មើលថាតើ " សម្បទានសេដ្ឋកិច្ច " វាជាមធ្យោបាយសំរាប់ការអភិវឌ្ឍដែលប្រកបដោយសមធម៌ដែររឺទេ រឺ មួយក៏វាមានឈ្មោះថាអភិវឌ្ឍន៏ប៉ុន្តែបែជាបង្កផលប៉ះពាល់ជាអវិជ្ជមានដល់សហគមន៏ក្នុងតំបន់( មូលដ្ឋាន) ទៅវិញ។

របាយការណ៏នេះបង្ហាញពីលទ្ធផលនូវការចុះការសិក្សាស្រាវជ្រាវ ដែលត្រូវបានធ្វើឡើងដោយក្រុមស្នូលរបស់ក្រុមការងារបរិស្ថាន ចាប់ផ្តើមពីខែកញ្ញា ឆ្នាំ ២០០៤ ដល់ខែមេសា ឆ្នាំ ២០០៥ ។ ការសិក្សាស្រាវជ្រាវនេះបានផ្តោតទៅលើសម្បទានសេដ្ឋកិច្ចចំនួនបួន មានឈ្មោះដូចជា ក្រុមហ៊ុន Green Rich Co. Ltd នៅក្នុងខេត្តកោះកុង ក្រុមហ៊ុន Cambodia Haining Group Co. Ltd ក្នុងខេត្តកំពុងស្ពឺ ក្រុមហ៊ុន Pheapi Mex Co. Ltd ក្នុងខេត្តពោធិ៏សាត់ និងកំពង់ឆ្នាំង និង ក្រុមហ៊ុន Wuzhishan LS Group ក្នុងខេត្តមណ្ឌលគិរី។ ការចុះសិក្សាស្រាវជ្រាវលើកទីប្រាំ គឺត្រូវបានធ្វើឡើងនៅក្នុងខេត្តព្រៃវែង និង ស្វាយរៀង ដែលជាកន្លែងប្រជាជនដាំប្រភេទឈើលូតលាស់លឿងខ្លះៗ ដើម្បីរកប្រាក់ចំណូលបន្ថែម និងក្នុងគោលបំណង យកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃផ្សេងៗទៀត ។ ការចុះសិក្សាស្រាវជ្រាវគឺធ្វើឡើងដោយផ្អែកលើការសម្ភាសន៏ជាមួយសហគមន៏មូលដ្ឋានចំនួន ២៨៣នាក់ ។ ការស្រាវជ្រាវឯកសារពាក់ព័ន្ធផ្សេងៗនៅឯទីស្នាក់ការការងារ ក៏ត្រូវបានធ្វើឡើងដោយស្វែងរកនូវព័ត៌មាន និង បទពិសោធន៏ជាអន្តរជាតិផ្សេងៗស្តីអំពីដំណាំចំការឈើដាំដែលគ្រប់បណ្តប់នៅលើផ្ទៃដីធំធេង ហើយនិងស្វែងរកនូវនិន្នាការ និង ព្រឹត្តការណ៏បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ស្តីពីគំរោងអភិវឌ្ឍន៏ចំការឈើដាំ និងគុណវិបត្តិនៃការអភិវឌ្ឍសម្បទានសេដ្ឋកិច្ចលើជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់( មូលដ្ឋាន) ទាំងនោះ ។

យើងសង្ឃឹមថារបាយការណ៏នេះ នឹងផ្តល់ជាជំនួយក្នុងការពិភាក្សាទៅលើបញ្ហាគោលនយោបាយនានាថាតើសម្បទានសេដ្ឋកិច្ចអាចចូលរួមចំនែកក្នុងការអភិវឌ្ឍអ្នកក្រីក្រដែររឺទេ? ហើយវានឹងផ្តល់ជាសំនួរថាតើវាមានដំណោះស្រាយមួយក្នុងការអភិវឌ្ឍដែលតំរូវឱ្យមានការទទួលខុសត្រូវទៅលើតំរូវការ និង យុទ្ធសាស្រ្តបំនិនជីវិត ដែររឺទេរបស់សហគមន៏ ហើយនិងទំនាក់ទំនងរវាងប្រជាជន និង បរិស្ថាននៅជុំវិញ។

មួយវិញទៀតក៏ដើម្បីចូលរួមចំនែកក្នុងការប្តេជ្ញាចិត្តរបស់ រាជរដ្ឋាភិបាលក្នុងការបង្កើតគំរោងសម្បទានសេដ្ឋកិច្ចនានានោះ របាយការណ៏នេះបានផ្តល់នូវអនុសាស្រ្តយ៉ាងច្រើនស្តីពីផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន និងសង្គម។ អនុសាសន៏ទាំងនោះអាចឱ្យរកបាននូវក្នុងផ្នែកអនុសាសន៏នៃចំនុចសង្ខេបរួមរបស់របាយការណ៏ទាំងភាសាអង់គ្លេស និងទាំងភាសាខ្មែរ ។

# Table of Contents

**Acknowledgements** ........................................ **1**
**Environment Forum Core Team** ........................................ **2**
**Abstract** ........................................ **3**
**សង្ខេប** ........................................ **4**
**List of Tables and Maps** ........................................ **7**
**Acronyms** ........................................ **8**
**Executive Summary** ........................................ **9**
Introduction ........................................ 9
Overview of the research ........................................ 10
Key findings from each case study ........................................ 11
Summary and conclusions ........................................ 18
Recommendations ........................................ 20
**សេចក្តីសង្ខេបរួម** ........................................ **23**
សេចក្តីផ្តើម ........................................ 23
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........................................ 25
លទ្ធផលសំខាន់ដែលបានមកពីករណីសិក្សានីមួយៗ ........................................ 26
សង្ខេប និង សន្និដ្ឋាន ........................................ 37
អនុសាសន៍ ........................................ 39
**1. Introduction** ........................................ **44**
**2. Aims and Objectives of the Report** ........................................ **45**
**3. An Introduction to Plantations** ........................................ **46**
3.1 What are plantations? ........................................ 46
3.2 Environmental impacts ........................................ 46
3.3 Social impacts of plantations ........................................ 48
3.4 A regional and global perspective on plantations ........................................ 49
3.5 Economic concessions in Cambodia ........................................ 50
**4. Research Methodology** ........................................ **55**
4.1 Focus ........................................ 55
4.2 Site selection ........................................ 55
4.3 Research methodology ........................................ 55
4.4 Limitations of the report ........................................ 56
4.5 Leadership of the research ........................................ 57
**5. Findings: Green Rich Co. Ltd, Koh Kong Province** ........................................ **62**
5.1 Introduction ........................................ 62
5.2 Livelihood ........................................ 66
5.3 Impact on the environment and livelihood ........................................ 66
5.4 Employment on the plantation ........................................ 68
5.5 Resettlement and loss of assets ........................................ 70
5.6 Perceived relationship: company, authorities and villagers ........................................ 70
5.7 Summary ........................................ 70
**6. Findings: Cambodia Haining Group Co., Kampong Speu Province** ........................................ **72**
6.1 Introduction ........................................ 72
6.2 Livelihood ........................................ 74

# សេចក្តីសង្ខេបរួម

## សេចក្តីផ្តើម

ដំណើរការពន្លឿនពីគំរោងចំការឈើដាំធំៗ នៅក្នុងប្រទេសកម្ពុជាតាមគំរូអភិវឌ្ឍន៍បែប " សម្បទានសេដ្ឋកិច្ច " កំពុងតែក្លាយជាបញ្ហាមួយដ៏មានសារៈសំខាន់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ និងទាមទារអោយមានដំណោះស្រាយជាបន្ទាន់។ សម្បទានសេដ្ឋកិច្ច តំរូវអោយមានផ្ទៃដីធំល្វឹងល្វើយ ហើយប៉ះពាល់ដល់ប្រជាជនជាច្រើនដែលភាគច្រើនរស់នៅតាមជនបទ ហើយជាទូទៅពួកគាត់ស្ថិតក្នុងជំពូកជនក្រីក្រ និងជនដែលងាយរងគ្រោះ។ បើទោះបីជាអ្នកគាំទ្រនូវគំរូសម្បទានសេដ្ឋកិច្ចលើកឡើងថា ការធ្វើចំការធំៗបែបនេះមានសារៈសំខាន់ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក៏ដោយ ក៏អ្នកផ្សេងទៀតអះអាងថា វាមានផលវិបាកអវិជ្ជមានជាច្រើន ហើយជាទូទៅប្រជាជនក្រីក្រដែលរស់នៅតាមជនបទមិនបានទទួលផលប្រយោជន៍អ្វីឡើយ ប៉ុន្តែផ្ទុយទៅវិញពួកគេបែរជាទទួលផលប៉ះពាល់ជាអវិជ្ជមាន។ ការធ្វើចំការឈើដាំធំៗនៅប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ ដោយមានសម្បទានជាច្រើននៅពេលបច្ចុប្បន្ននេះមានអត្ថិភាពតែនៅលើផ្ទៃដីដែលកំណត់ក្នុងផែនទីប៉ុណ្ណោះ។ ប៉ុន្តែសម្បទានខ្លះបានឈានដល់ដំណាក់កាលឈូសឆាយដី និងកាប់ឆ្ការព្រៃឈើ ផ្លាស់ប្តូរលំនៅដ្ឋានថ្មីសំរាប់ប្រជាពលរដ្ឋ និងដាំដើមឈើ។ ដូចនេះវាគឺជាឱកាសក្នុងការពិនិត្យមើលទៅលើសារៈប្រយោជន៍ និងគុណវិបត្តិនៃគំរូសម្បទានគោលដៅសេដ្ឋកិច្ចដើម្បីវាយតំលៃថា តើវាគួរជាសមាសភាពមួយចាំបាច់ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដែរឬទេមុនពេលគំរោងនេះត្រូវបានអនុវត្តន៍នៅពាសពេញផ្ទៃដីកម្ពុជា។

ការធ្វើចំការធំៗមានច្រើនរូបភាព ហើយនៅក្នុងរបាយការណ៍នេះត្រូវបានកំណត់ថាជាឯកវប្បកម្ម (monoculture) ជាពូជមានតំលៃសេដ្ឋកិច្ចដែលត្រូវដាំនៅលើផ្ទៃដីធំល្វឹងល្វើយ។ ប្រភេទពូជបែបនេះរួមមានដើមអាកាស្យាដែលដុះធំធាត់លឿន ដើមប្រេងខ្យល់ និងដើមស្រល់ ត្រូវបានស្គាល់ថាជាប្រភេទឈើដែលដាំទៅវាឆាប់ធំ។ នៅក្នុងពិភពលោកគេបានអះអាងថា ការធ្វើចំការដាំដើមឈើដែលធំលឿននេះមានសារៈប្រយោជន៍សំរាប់ជាកម្មវិធីដាំដើមឈើឡើងវិញ ដើម្បីបង្ការការហូរច្រោះដី និងទឹកជំនន់ កាត់បន្ថយសំពាធ មកលើព្រៃឈើធម្មជាតិ កាត់បន្ថយភាពក្រីក្រ ប្រឆាំងទប់ទល់នឹងការផ្លាស់ប្តូរអាកាសធាតុ និងដើម្បីផ្តល់ការងារ ជូនប្រជាជននៅទីដាច់ស្រយាលដែលពីមុនមិនធ្លាប់មាន ។ ប៉ុន្តែការអះអាងបែបនេះតែងតែត្រូវបានជំទាស់ជា ញឹកញាប់។ អ្នកប្រឆាំងចំពោះការធ្វើចំការដែលមានលក្ខណៈធំធេងបែបនេះលើកឡើងថា វាមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងច្រើនលើផ្នែកបរិស្ថាន និងសង្គមដែលផ្នែកទាំងនេះមានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ។ ផលប៉ះពាល់ទាំងឡាយផ្នែកបរិស្ថានរួមមានៈ ការបំផ្លាញព្រៃឈើបណ្តាលអោយមានការថយចុះផ្នែកជីវៈចំរុះដែលនាំអោយប៉ះពាល់ដល់ស្ថេរភាព និងមុខងារប្រព័ន្ធអេកូឡូស៊ី ការបំផ្លាញធនធានទឹក និងអាងបង្ហូរទឹកបំលាស់ប្តូរចំពោះអាកាសធាតុនៅទីតាំងនោះ និងសមភាពទឹកការថយចុះគុណភាពដីកើតជំងឺរាតត្បាត និងការបំពុលដោយសារធាតុគីមីកសិកម្ម។ ចំណែកផលប៉ះពាល់សង្គមវិញរួមមានៈ ការបាត់បង់ដីធ្លីទ្រព្យសម្បត្តិ និងលទ្ធភាពទទួល

បានធនធានធម្មជាតិការភ័យខ្លាចអំពីសន្តិសុខ និងការទន្រ្ទានយកដី និងការរំលោភសិទ្ធិមនុស្ស។ ចំពោះអ្នកដែលគាំទ្រការធ្វើចំការឈើដាំអះអាងថា ផលប៉ះពាល់ជាអវិជ្ជមានកើតជាអប្បរមានៅពេលដែលការគ្រប់គ្រងគំរោងបានត្រឹមត្រូវ ចំណែកឯអ្នកប្រឆាំងវិញអះអាងថាឧស្សាហកម្មនេះកំពុងបំផ្លិចបំផ្លាញបរិស្ថាន និងសង្គម។ នៅលើសាកលលោកភាគច្រើនការធ្វើចំការដាំដើមឈើដែលលូតលាស់លឿនបែបនេះ តែងតែមានភាពចំរូងចំរាស់ និងជាប្រភពនៃវិវាទសង្គមយ៉ាងធ្ងន់ធ្ងរនៅបណ្តាលប្រទេសមួយចំនួន។

កម្ពុជាធ្លាប់មានពិសោធន៏ក្នុងការធ្វើចំការធំៗ នៅក្នុងសម័យអាណានិគមបារាំងដែលមានធ្វើចំការកៅស៊ូធំៗមួយចំនួននៅក្នុងខេត្តកំពង់ចាម និងខេត្តក្រចេះ ហើយនៅតែបន្តប្រតិបត្តិការណ៏រហូតមកដល់សព្វថ្ងៃនេះ។ តែទោះបីជាយ៉ាងនេះក៏ដោយ ការធ្វើចំការបែបនេះបានកើនឡើងយ៉ាងលឿននៅក្រោយសម័យអន្តរកាលសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចទីផ្សារនាដើមទស្សវត្សរ៍ឆ្នាំ១៩៩០។ ចំការដែលត្រូវបានស្នើសុំ និងដែលបានដំណើរការនៅក្នុងកំឡុងពេលនេះរួមមាន ដើមអាកាស្យា និងដើមប្រេងខ្យល់ (ជាប្រភេទឈើដែលឆាប់ធំ) ដូងប្រេង ក្លូច អំពៅពោត កៅស៊ូ ម៉ៃសាក់ និងស្វាយចន្ទី។ កាលពីខែកុម្ភៈ ឆ្នាំ២០០៣ UNCOHCHR បានរាយការណ៏ថា រហូតមកដល់ពេលបច្ចុប្បន្ននេះមានសម្បទានសេដ្ឋកិច្ចចំនួន៤០ ត្រូវបានអនុម័តយល់ព្រមដែលមានផ្ទៃដីសរុបចំនួន៨០៩.២៩៦ ហិកតា បើទោះបីជាមិនគ្រប់សម្បទានទាំងអស់ក៏ដោយ ក៏បានបន្តកសាងជាចំការពិតប្រាកដក៏ដោយ (UNCOHCHR, 2004)។ ប៉ុន្តែបញ្ជីឈ្មោះសម្បទានសេដ្ឋកិច្ចទាំងនេះទំនងដូចជាមិនទាន់ពេញលេញនៅឡើយ។

ប្រទេសកម្ពុជាមានច្បាប់មួយចំនួនដែលពាក់ព័ន្ធនឹងការអភិវឌ្ឍសម្បទានសេដ្ឋកិច្ចរួមមាន ច្បាប់ភូមិបាល (ឆ្នាំ ២០០១) ច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ ២០០៣) និង ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (ឆ្នាំ ១៩៩៦)។ ក្រៅពីនេះនៅមានអនុក្រឹត្យពាក់ព័ន្ធមួយចំនួនទៀតរួមទាំង អនុក្រឹត្យស្តីពីសម្បទានសេដ្ឋកិច្ចដែលនឹងត្រូវអនុម័តនៅក្នុងពេលសរសេរ។ ទិដ្ឋភាពមួយចំនួននៃច្បាប់ទាំងឡាយជាធរមានត្រូវបានរំលោភបំពាន។ ឧទាហរណ៏: ច្បាប់ភូមិបាលចែងថា ល្គឹកណាតែមានករណីពិសេស សម្បទានសេដ្ឋកិច្ចមិនត្រូវមានទំហំលើសពី១០.០០០ហិកតាឡើយ ប៉ុន្តែតាមការជាក់ស្តែងសម្បទានជាច្រើនមានទំហំលើសពីការកើតនេះ។[៣]

សម្បទានសេដ្ឋកិច្ចនៅកម្ពុជា ត្រូវបានពពាយនាយថាមានការចាំបាច់ក្នុងការបង្កើនចំណូលចាំបាច់ឱ្យបានច្រើនសំរាប់ប្រទេសជាតិ (តាមរយៈថ្លៃជួលដីនិងប្រាក់ពន្ធ) បង្កើនសហគ្រាសឯកជនព្រមទាំងបង្កើតការងារ សំរាប់សហគមន៏នៅជនបទដែលនឹងរួមចំណែកដល់គោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ ។ ប៉ុន្តែអ្នកសង្កេតការណ៏ខ្លះបានសរសេរថារហូតមកដល់ពេលនេះមានភស្តុតាងតិចតួចដែលបញ្ជាក់អំពីសារៈប្រយោជន៏ ដែលបានលើកឡើងហើយបានអះអាងនូវហេតុផលផ្សេងទៀតសំរាប់សម្បទានសេដ្ឋកិច្ចបន្ថែមទៅលើគោលបំណងកសិកម្ម របស់ពួក

[3] ច្បាប់ភូមិបាល ឆ្នាំ២០០១: សម្បទានដីអាចមានទំហំច្រើនបំផុតត្រឹមតែ ១០.០០០ (មួយម៉ឺនហិកតា) ហិកតា ។ សម្បទានដីដែលសំរេចហើយហើយមានទំហំលើសពីទំហំកំណត់ខាងលើ ជាកម្មវត្ថុនៃការកាត់បន្ថយ ។ ប៉ុន្តែប្រសិនបើការកាត់បន្ថយនេះមានឥទ្ធិពលធ្វើឱ្យខូចប្រយោជន៏អាជីវកម្មដែលកំពុងមានដំណើរការ សម្បទានិកអាចនឹងទទួលបានការលើកលែងជាពិសេស

គេរួមទាំងការចៀសវាងពីច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០២) ដែលកាន់តែតឹងរ៉ឹងជាងមុនដើម្បីកាប់ឈើ នៅក្នុងតំបន់ព្រៃឈើល្អៗ និងសំរាប់ផលប្រយោជន៍ក្រុមហ៊ុនដ៏ធំក្នុងការទាញយកផលប្រយោជន៍ពីការកំណត់ហាង ឆេងដី។ (UNCOHCHR, 2004) វាមានការលំបាកពន់ពេកសូម្បីតែការទទួលបានព័ត៌មានជាមូលដ្ឋានស្តី ពីសម្បទានសេដ្ឋកិច្ចដែលពិតជាកំណត់នូវលទ្ធភាពរបស់សង្គមស៊ីវិលក្នុងការតាមដានត្រួតពិនិត្យ និងចូលរួមនៅក្នុងសេចក្តីសំរេចចិត្តដែលប៉ះពាល់ដល់ស្រទាប់ដ៏ធំនៃសង្គមកម្ពុជា។

## សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ការវិភាគជាច្រើនអំពីបាតុភូតនៃការធ្វើចំការឈើដាំដែលមានទ្រង់ទ្រាយធំៗ តាមទស្សនទានអន្តរជាតិ តំបន់ និងនៅកម្ពុជាត្រូវបានសរសេរក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ របាយការណ៍នេះបង្ហាញជូននូវលទ្ធផលនៃការស្រាវជ្រាវនៅមូលដ្ឋានដោយក្រុមស្នូលនៃវេទិកាស្តីពីបរិស្ថាន (Environmental Forum Core Team) នៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) នៅចន្លោះខែកញ្ញា ឆ្នាំ២០០៤ និង ខែមីនា ឆ្នាំ២០០៥ ទៅលើសម្បទានសេដ្ឋកិច្ចនៅប្រទេសកម្ពុជាដែលកំពុងអភិវឌ្ឍន៍នៅពេលបច្ចុប្បន្ននេះរួមជាមួយនឹងមួយ ភាគប្រាំនៃតំបន់ដែលសហគមន៍ដាំដើមឈើលូតលាស់លឿន (តារាងទី១)។

**តារាងទី ១: ព័ត៌មានពីស្ថារគន្លឹះនៃសម្បទានសេដ្ឋកិច្ចដែលបានចុះស្រាវជ្រាវ**

| *ទីតាំងសម្បទាន (ខេត្ត)* | *សម្បទានិក/ម្ចាស់ភាគហ៊ុន/ថ្ងៃអនុម័ត* * | *ផ្ទៃដីសម្បទាន(ហិកតា)/ គោលបំណង* |
|---|---|---|
| ខេត្តកោះកុង | The Green Rich Co., Ltd<br>តៃវ៉ាន់ ១០០% / ២៥.១១.៩៨ | ១៨.៣០០ / ដើមអាកាស្យា និង ដើមដូងប្រេង |
| ខេត្តកំពង់ស្ពឺ | Cambodian Haining Group Co.<br>ចិន១០០% / ២៣.៧.៩៨ | ២១.២៥០ / ក្តួច ដើមដូងប្រេង និង ចិញ្ចឹមសត្វ |
| ខេត្តពោធិ៍សាត់និងខេត្តកំពង់ឆ្នាំង | Pheapimex Co., Ltd / n.a.<br>8.1.00 | ពោធិ៍សាត់១៣៨.៩៦៣ កំពង់ឆ្នាំង១៧៦.០៦៥/ ដើមប្រេងខ្យល់ |
| ខេត្តមណ្ឌលគីរី | Wuzhishan L.S. Group | ១៩៩.៩៩៩ (អនុម័ត ១០.០០០) / ដើមស្រល់ |
| ខេត្តព្រៃវែង និង ខេត្តស្វាយរៀង | សហគមន៍ | អ្នកភូមិដាំដើមអាកាស្យា ប្រេងខ្យល់ និងដើមស្វាច់នៅចន្លោះវាលស្រែ និងតាមរបងផ្ទះ របស់ពួកគាត់ |

គោលបំណងរួមនៃការស្រាវជ្រាវនេះ ដោយផ្អែកលើការស្រាវជ្រាវនៅក្នុងការិយាល័យ និងចុះតាមមូលដ្ឋានគឺដើម្បីកំណត់នូវអ្វីខ្លះដែលអាចជាសារៈប្រយោជន៍ និងគុណវិបត្តិនៃការអភិវឌ្ឍសម្បទានសេដ្ឋកិច្ចសំរាប់ជីវភាពរបស់ប្រជាជននៅមូលដ្ឋាន។ ផលប៉ះពាល់បច្ចុប្បន្ន និងទៅអនាគតផ្នែកបរិស្ថាន និងសេដ្ឋកិច្ច-សង្គមមកលើសហគមន៍ពាក់ព័ន្ធត្រូវបានលើកយកមកពិនិត្យ ពិចារណារួមទាំងបញ្ហាផ្សេងៗទៀតដូចជា ការងារដែលប្រជាជននៅមូលដ្ឋានទទួលបាន ការបាត់លទ្ធភាពទទួលបានធនធានធម្មជាតិ និងបែបផែននៃទំនាក់ទំនងរវាងអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធរួមមានអាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុនធ្វើចំការ និងសហគមន៍។

ការស្រាវជ្រាវនៅមូលដ្ឋានផ្អែកលើការធ្វើបទសំភាសន៍ ដោយឆ្លើយសំណួរពាក់កណ្តាលជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងតារាងសំណួរពីស្តារជាមួយគ្រួសារ (ចំនួន២៨៣គ្រួសារ) ហើយត្រូវបានធ្វើឡើងនៅចន្លោះខែកញ្ញា ឆ្នាំ២០០៤ និងខែមីនា ឆ្នាំ២០០៥។ ការកំហិតចំពោះការស្រាវជ្រាវនៅមូលដ្ឋានពាក់ព័ន្ធជាសំខាន់ជាមួយនឹងគំរូសិក្សាតូចៗលើផ្ទៃដីធំល្វឹងល្វើយដែលគ្របដណ្តប់ដោយសម្បទានសេដ្ឋកិច្ច។ ភូមិករជាច្រើនដែលបានទទួលរងការប៉ះពាល់ដោយការការអភិវឌ្ឍដំណាំចំការត្រូវបានជ្រើសរើសសំរាប់ការធ្វើអង្កេត ដោយមានការប៉ាន់ស្មានថាភូមិទាំងនោះ និងផ្តល់ចំលើយប្រហាក់ប្រហែលគ្នានៅពេលអនាគត។

## លទ្ធផលសំខាន់ដែលបានមកពីករណីសិក្សានីមួយៗ

- **ក្រុមហ៊ុន Green Rich Co. Ltd., នៅខេត្តកោះកុង**

Green Rich ត្រូវបានគេផ្តល់ដីសម្បទានចំនួន៦០.២០០ហិកតា សំរាប់ដាំដើមអាកាស្យា និងដើមដូងប្រេងនៅភាគនិរតីនៃខេត្តកោះកុងកាលពីខែវិច្ឆិកា ឆ្នាំ១៩៩៨ ។ សម្បទាននេះដែលត្រូវបានបន្ថយមកត្រឹម ១៨.០០០ ហិកតាវិញនៅក្នុងខែមិថុនា ឆ្នាំ២០០៣ មានទីតាំងស្ថិតនៅស្ទើរតែនៅក្នុងឧទ្យានជាតិបូទុមសាគរទាំងមូល ហើយព្រៃឈើនៅទីនោះជាទូទៅត្រូវបានចាត់ទុកជាប្រភេទដែលគ្របដណ្តប់នៅក្នុងព្រៃពណិខៀវត្រង់នេះបន្តិចត្រង់នោះបន្តិច និងមិនសូវអោយផលរួមជាមួយតំបន់ព្រៃកោងកាងនៅតាមបណ្តោយឆ្នេរសមុទ្រ។ ជាប់តាំងតំបន់នោះជាឧទ្យានជាតិប្រជាជនរស់នៅរប៉ាត់រប៉ាយនៅក្នុងសម្បទាននេះ បើទោះបីជាមានសហគមន៍ធំៗមួយចំនួនរស់នៅតាមបណ្តោយឆ្នេរក៏ដោយរួមជាមួយ និងសហគមន៍ខ្លះទៀតដែលរស់នៅតាមបណ្តោយទន្លេខ្លួងដែលបង្កើតបានជាព្រំប្រទល់ដីគោកនៃតំបន់សម្បទានទៅភាគខាងកើត។ ក្រសួងបរិស្ថានគ្រប់គ្រងឧទ្យានជាតិបូទុមសាគរដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ Wild Aid។ អ្នកប្រឆាំងចំពោះសម្បទាននេះលើកឡើងថាវាមានទីតាំងខុសច្បាប់នៅក្នុងឧទ្យានជាតិ ហើយលើសពីទំហំកំណត់ ១០.០០០ហិកតា ដែលកំណត់នៅក្នុងច្បាប់ភូមិបាល បើទោះបីជារដ្ឋាភិបាលអះអាងថា សម្បទាននេះគឺជាតំបន់ទ្រនាប់ដែលគ្របដណ្តប់ដោយព្រៃរិចរឹលវាលដែលមិនប្រើប្រាស់ និងដីគ្មានជីវជាតិក៏ដោយ។ (Reynolds, 25.4.04)

Green Rich បានចាប់ផ្តើមសកម្មភាពរបស់ខ្លួននៅឆ្នាំ២០០៤ ដោយការកាប់គាស់ព្រៃកោងកាងនៅដង ទន្លេខ្លង បើទោះបីជាខ្លួនមិនទាន់បានបញ្ចប់ការធ្វើវិភាគហេតុផលប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងក៏ដោយ។ នៅខែឧសភា ឆ្នាំ២០០៤ ក្រសួងបរិស្ថានបានបញ្ជាអោយផ្អាកប្រតិបត្តិការរបស់ក្រុមហ៊ុន Green Rich រហូតទាល់តែបញ្ចប់នូវរាល់វិធានការច្បាប់ចាំបាច់រួចរាល់សិន។ ទោះបីជាមានបទបញ្ជានេះក៏ដោយ ក៏ក្រុមហ៊ុន Green Rich បានបន្តប្រតិបត្តិការកាប់ឈើ ហើយថែមទាំងត្រូវបានគេចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្សនៅលើដីសម្បទានរបស់ខ្លួននៅពេលដែលគេបានឃើញកម្មករស្ថិតក្នុងលក្ខខណ្ឌនៃការងារជាប់កិច្ចសន្យា ដែលចាំបាច់អោយមានការជួយសង្គ្រោះពីប៉ូលីស និង អង្គការមិនមែនរដ្ឋាភិបាល។ Green Rich បានដាក់ការវិភាគហេតុផលប៉ះពាល់បរិស្ថាន (EIA) នៅខែសីហាឆ្នាំ២០០៤ហើយបានបន្តប្រតិបត្តិការរបស់ខ្លួនបើទោះបីជា EIA មិនទាន់ត្រូវបានអនុម័តយល់ព្រមជាផ្លូវការក៏ដោយ។ ប្រការនេះបានធ្វើអោយក្រសួងបរិស្ថានដាក់ពាក្យបណ្តឹងចំពោះក្រុមហ៊ុននៅខែមករា ឆ្នាំ២០០៥ រួមទាំងការទារសំណងជួសជុលចំនួន១លានដុល្លាអាមេរិក ហើយជាលទ្ធផលរឿងក្តីនេះនៅព្យួរទុកនៅឡើយ។

ការស្រាវជ្រាវនៅមូលដ្ឋានត្រូវបានធ្វើឡើងនៅក្នុងភូមិ**កោះកុង**ក្នុងនៅខេត្តកោះកុង ដែលជាសហគមន៍តូចមួយនៅតាមបណ្តោយទន្លេ **ខ្លង** ស្ថិតនៅទល់មុខនឹងស្នាក់ការរបស់ក្រុមហ៊ុន និងនៅភូមិ **ជ្រោយប្រាស់** និង ភូមិ **ថ្មី** ដែលជាសហគមន៍ធំៗជាប់គ្នាពីរ មានទីតាំងស្ថិតនៅតាមបណ្តោយឆ្នេរនៃដីសម្បទាននេះ។ សកម្មភាពចិញ្ចឹមជីវិតសំខាន់របស់ប្រជាជននៅភូមិកោះកុងក្នុង គឺការនេសាទត្រី ព្រមទាំងធ្វើកសិកម្មបន្តិចបន្តួច និងសកម្មភាពប្រមូលអនុផលព្រៃឈើ (NTFP)។ នៅភូមិជ្រោយប្រាស់ និងភូមិថ្មី សកម្មភាពចិញ្ចឹមជីវិតសំខាន់របស់ពួកគាត់គឺការនេសាទ និងធ្វើកសិកម្មដោយមានការពឹងផ្អែកតិចតួចទៅលើអនុផលព្រៃឈើ។ ធនធានត្រីបានធ្លាក់ចុះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះដែលធ្វើអោយប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន ប៉ុន្តែបញ្ហានេះត្រូវបានទំលាកកំហុសទៅលើសកម្មភាពនេសាទខុសច្បាប់មិនមែនទៅលើសកម្មភាពរបស់ក្រុមហ៊ុនទេ។ តែទោះជាយ៉ាងនេះក្តី អ្នកផ្តល់បទសំភាសន៏៣នាក់បានបញ្ជាក់ថាសកម្មភាពនៅកន្លែងធ្វើចំការបានបំពុលចរន្តទឹកធ្វើអោយប៉ះពាល់ដល់ធនធានត្រីដែលបណ្តាលមកពីការបញ្ចេញចោលនូវប្រេងដែលមានជាតិពុលនៅពេលគេបកសំបកស្មាច់។

រហូតមកដល់ពេលនេះ ការចូលមកដល់របស់ក្រុមហ៊ុនបានធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សហគមន៏ដែលរស់នៅក្បែរនោះ។ នៅភូមិកោះកុងក្នុងក្រុមហ៊ុនមិនទាន់បានធ្វើអោយប៉ះពាល់ដល់ការប្រមូលអនុផលព្រៃឈើទេ។ ប៉ុន្តែនៅភូមិជ្រោយប្រាស់ និងភូមិថ្មីមានការថយចុះនូវចំនួនអ្នកប្រមូលអនុផលព្រៃឈើពី ៣៦%-១៤%។ ៣១% នៃចំនួនអ្នកដែលបានឈប់ ហើយបានបន្ទោសដោយផ្ទាល់ចំពោះក្រុមហ៊ុនដែលបានរារាំងពួកគេមិនអោយចូលព្រៃ។ ឈើដែលអាចរកបានក៏បានធ្លាក់ចុះ បើទោះបីជាបញ្ហានេះត្រូវបានទំលាក់កំហុសជាសំខាន់ទៅលើសកម្មភាពអភិរក្សរបស់ក្រសួងបរិស្ថាន និងអង្គការ Wild Aid ក៏ដោយ។ គេយល់ថាការធ្លាក់ចុះនូវបរិមាណសត្វព្រៃក៏ត្រូវបានទំលាក់កំហុសទៅលើសកម្មភាពរបស់ក្រុមហ៊ុនផងដែរ។ ជាពិសេសសកម្មភាពកាប់ឆ្ការព្រៃ និងសំលេងម៉ាស៊ីន។

សហគមន៍មូលដ្ឋានមិនត្រូវបានគេធ្វើការពិគ្រោះយោបល់ឡើយ នៅពេលដែលមានផែនការធ្វើសម្បទានសេដ្ឋកិច្ច ហើយជាទូទៅប្រជាជននៅភូមិជ្រោយប្រាស់ និងភូមិថ្មីបានដឹងតិចតួចអំពីសម្បទាននេះបើទោះបីជាសម្បទាននេះលាតសន្ធឹងរហូតទៅដល់ព្រំប្រទល់ភូមិរបស់ពួកគាត់ក៏ដោយ។ បើទោះបីជាប្រជាជនជាច្រើន(៣៨%) នៅក្នុងភូមិកោះកុងក្នុងបានទទួលការងារធ្វើប៉ុន្មានខែនៅក្នុងចំការក៏ដោយ ក៏ប្រជាជននៅភូមិជ្រោយប្រាស់ និងភូមិថ្មីមានប្រជាជនតែ៧%ប៉ុណ្ណោះដែលបានទទួលការងារធ្វើ ហើយមិនសូវទៀងទាត់ទៀតផង។ ពាក់ព័ន្ធនឹងការបាត់បង់សិទ្ធិលើដីធ្លី វាលស្រែតិចតួចដែលក្រុមហ៊ុនបានទាមទារក្នុងនោះពាក់កណ្តាលត្រូវបានសងវិញដោយផ្តល់ជាដីថ្មី។

នៅភូមិកោះកុងក្នុង អ្នកភូមិចំនួន៦៣% សប្បាយរីករាយនឹងការចូលមកដល់របស់ក្រុមហ៊ុន ជាពិសេសគឺក្រុមហ៊ុនផ្តល់ការងារ។ តែផ្ទុយទៅវិញប្រជាជននៅក្នុងភូមិដែលមានប្រជាជនច្រើនដូចជា ភូមិជ្រោយប្រាស់ និងភូមិថ្មី ប្រជាជាចំនួន៦៨% មិនសប្បាយរីករាយជាមួយនឹងការមកដល់របស់ក្រុមហ៊ុនឡើយ ជាពិសេសគឺការបំផ្លាញព្រៃឈើ និងផលប៉ះពាល់របស់វាមកលើជីវភាពរស់នៅទៅអនាគតរបស់គ្រួសាររបស់គេ។ បច្ចុប្បន្ននេះសម្បទានត្រូវបានផ្អាក តែប្រសិនបើរាជរដ្ឋាភិបាលផ្តល់សម្បទានជាថ្មីម្តងទៀតអោយក្រុមហ៊ុនបន្តប្រតិបត្តិការនោះ ផ្ទៃដីធំទូលាយដែលមានតំលៃសំរាប់ប្រព័ន្ធអេកូឡូស៊ីរបស់ឧទ្យានជាតិបូទុមសាគរនឹងត្រូវបំផ្លាញ ដូច្នេះត្រូវអភិរក្សទាំងជីវចំរុះ និងតំលៃខ្សែទឹក។ ការបាត់បង់លទ្ធភាពទទួលបានអនុផលព្រៃឈើបើទោះបីជាវាមិនមែនសកម្មភាពរកចំណូលសំខាន់ក៏ដោយ ក៏នឹងធ្វើអោយប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដែរ។ បើទោះបីជាមានប្រជាជនតិចតួចរស់នៅក្បែរដីសម្បទាន ហើយនៅក្នុងសហគមន៍ធំដែលយើងបានទៅដល់គឺ (ភូមិជ្រោយប្រាស និងភូមិថ្មី) ទោះជាការពឹងផ្អែកលើធនធានព្រៃឈើជាសកម្មភាពទីពីរបន្ទាប់ពីការនេសាទត្រី និងកសិកម្មក៏ដោយ នៅពេលដែលចំការនេះកើតឡើង វាពិតជានឹងប៉ះពាល់ជាអវិជ្ជមានមកលើជីវភាពរបស់ពួកគាត់ដោយសារការបាត់បង់ព្រៃកោងកាងដែលតំបន់នោះមានសារៈសំខាន់សំរាប់ការបង្កាត់ពូជរបស់ត្រីព្រមទាំងការបំពុលចរន្តទឹក និងផលប៉ះពាល់មកលើភាពសំបូរបែបនៃទឹកពីការដាំដើមអាកាស្យា។

### ក្រុមហ៊ុន Cambodia Haining Group Co., នៅខេត្ត កំពង់ស្ពឺ

ខេត្តកំពង់ស្ពឺស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា។ កាលពីខែកក្កដាឆ្នាំ១៩៩៨ក្រុមហ៊ុន Haining បានទទួលសម្បទានចំនួន ២១.២៥០ហិកតា នៅក្នុងស្រុកឱរ៉ាល់ និងស្រុកភ្នំស្រួចក្នុងគោលបំណងដាំក្លូច ដើមអាកស្យា និងដូងប្រេង ដោយរួមទាំងសកម្មភាពចិញ្ចឹមសត្វ។ តំបន់នេះត្រូវបានចាត់ថ្នាក់ថាជាតំបន់ដែលគ្របដណ្តប់ដោយព្រៃរិចរឹល និងវាលស្រែរដូវវស្សា។ ព្រំប្រទល់សម្បទានដែលបានកំណត់ជាប់ជាមួយតំបន់ដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ នៅប៉ែកខាងត្បូងសាន។ ចាប់តាំងពីឆ្នាំ ១៩៩៧ អង្គការអន្តរជាតិ Lutheran World Federation បានធ្វើការនៅក្នុងតំបន់នោះ។

Haining បានចាប់ផ្តើមកាប់ឆ្ការព្រៃនៅក្នុងតំបន់សម្បទាននៅឆ្នាំ២០០២។ តែទោះបីជាដូច្នេះក្តីអ្នកភូមិដែលរងផលប៉ះពាល់បានធ្វើការតវ៉ាព្រមទាំងមានការរិះគន់ពីអង្គការអន្តរជាតិ Global Witness បានបង្ខំអោយក្រុមហ៊ុនបញ្ឈប់សកម្មភាពរបស់ខ្លួន។ នៅពេលនោះអង្គការ Lutheran World Federation បានរាយការណ៍ថា

ក្រុមហ៊ុនបានដាំដើមប្រេងល្ហុង (ល្ហុងខ្វង) ចំនួន៥-៦ហិកតា សាងសង់ការិយាល័យ និងនាំចូលនូវឧបករណ៍ធុនធ្ងន់ តំលើងម៉ាស៊ីនអារឈើ និងកសាងផ្លូវឯកជនមួយ។ ក្រុមហ៊ុនមានបំណងហាមឃាត់អ្នកភូមិមិនអោយប្រើប្រាស់ដីកសិកម្ម និងធនធានព្រៃឈើនៅក្នុងតំបន់សម្បទាន។ តែទោះបីជាយ៉ាងណាក៏ដោយនៅពេលនេះគ្មានអ្នកភូមិណាម្នាក់បានបាត់បង់ដីធ្លីឡើយ លើកលែងតែដីសំរាប់ដាំក្លួចបានបញ្ឈប់ប្រតិបត្តិការហើយ។

ក្នុងពេលស្រាវជ្រាវនៅមូលដ្ឋានអ្នកស្រាវជ្រាវរបស់យើងបានទៅដល់ភូមិចំនួន៤ ដែលស្ថិតនៅក្នុងតំបន់សម្បទាន។ ៨%នៃអ្នកផ្តល់បទសំភាសន៏ការធ្វើស្រែជាសកម្មភាពចំបងរបស់ពួកគេ។ ៥៤% ដុតធ្យូងដើម្បីរកចំណូលបន្ថែមដែលអាចរកប្រាក់បានពី ១៥ ទៅ ២៥ដុល្លាក្នុងមួយខែ។ ដោយសារឆ្នាំនេះជួបនូវគ្រោះរាំងស្ងួត និងស្រូវមិនសូវល្អអ្នកភូមិបានប្រាប់អោយដឹងថា អ្នកភូមិជាច្រើនទៅរកឈើដើម្បីដុតធ្យូងដែលជាមុខរបរមួយបន្ថែមទៅលើការចំណូលតិចតួចពីការប្រមូលផលស្រូវដែលជាការបញ្ជាក់អោយឃើញពីតំលៃនៃអនុផលព្រៃឈើថា ជាសំណាញ់សុវត្ថិភាព (safetynet) ក្នុងការធានាសន្តិសុខជីវភាព។ លើសពីនេះទៅទៀតការដុតធ្យូង ការប្រមូលអនុផលព្រៃឈើក៏មានសារៈសំខាន់សំរាប់គ្រួសារជាច្រើនដែលជាប្រភពចំណូលផង និងសំរាប់ជាការប្រើប្រាស់នៅក្នុងគ្រួសារផង ហើយត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៅពេលក្រុមហ៊ុនបានមកដល់ ដោយបានកំហិតលទ្ធភាពចូលទៅក្នុងព្រៃដែលប្រជាជនធ្លាប់តែប្រមូលអនុផលព្រៃឈើពីមុនមក។ លទ្ធភាពក្នុងការរកឈើក៏ត្រូវបានកំហិតដោយសារវត្តមានរបស់ក្រុមហ៊ុននៅទីនោះ សូម្បីតែនៅមុនពេលក្រុមហ៊ុនមកដល់អាជ្ញាធរមូលដ្ឋានបានខិតខំអនុវត្តច្បាប់ការពារព្រៃឈើក៏ដោយ។

ប្រសិនបើសម្បទានក្រុមហ៊ុន Haining ត្រូវបន្តម្តងទៀត Lutheran World Federation បានប៉ាន់ស្មានថាភូមិចំនួន ២៦ នៅក្នុងឃុំ ៤ នឹងត្រូវប៉ះពាល់ដែលប្រជាជនប៉ាន់ស្មានសរុបចំនួន ៨៥២៩នាក់ (១.៧២៧គ្រួសារ)។ លើសពីនេះទៅទៀតដីដែលអាចដាំដុះបានចំនួន១៥៥១ហិកតា នឹងត្រូវបាត់បង់រួមទាំងផ្ទៃដីព្រៃដ៏ធំល្វឹងល្វើយដែលនៅពេលបច្ចុប្បន្ននេះសហគមន៏កំពុងពឹងអាស្រ័យលើ។ គ្មានការពិគ្រោះយោបល់រវាងក្រុមហ៊ុន និងប្រជាជនមូលដ្ឋានពាក់ព័ន្ធនឹងបញ្ហាថាតើពួកគេចង់អោយមានសម្បទានដែរឬក៏អត់។ ក្រុមហ៊ុន Haining មានសកម្មភាពក្នុងរយៈពេលខ្លី មានតែ៤គ្រួសារ (៥%) ប៉ុណ្ណោះដែលបានធ្វើបទសំភាសន៏រាយការណ៏ថា សមាជិកគ្រួសាររបស់គេបានទទួលការងារជាមួយក្រុមហ៊ុននេះ។ ត្រង់នេះហាក់ដូចជាស្តែងអោយឃើញថាមុនពេលចាប់ផ្តើមសកម្មភាពរបស់ខ្លួន ។ ក្រុមហ៊ុន Haining បានសន្យាផ្តល់ការងារជូនប្រជាជនមូលដ្ឋានប៉ុន្តែបានទទួលយកអ្នកក្រៅមកធ្វើការទៅវិញ។ នៅពេលនេះក្រុមហ៊ុនកំពុងដាំក្លួចនៅលើផ្ទៃដី៦ហិកតា ដែលជាចញ្ញជាតិពុលប្រសិនបើមិនទាន់កែឆ្នៃ។ អ្នកភូមិម្នាក់បានប្រាប់អោយដឹងថានៅឆ្នាំ២00១ គោចំនួន ៦ក្បាល មកពីភូមិ **អូរផ្តៅ** បានងាប់ដោយសារវាស៊ីក្លួចដែលក្រុមហ៊ុនបានដាំ។

៧0% នៃគ្រួសារដែលបានធ្វើបទសំភាសន៏និយាយថាពួកគេមិនសប្បាយចិត្តនឹងការមកដល់របស់ក្រុមហ៊ុនឡើយ ព្រោះពួកគេត្រូវបាត់បង់ដីស្រែ ក្រុមហ៊ុនបានបំផ្លាញព្រៃឈើ សត្វព្រៃបានបាត់បង់ ហើយនៅក្នុងករណីខ្លះសន្តិសុខរបស់ក្រុមហ៊ុនបានគំរាមកំហែងពួកគេទៀតផង។ ការបាត់បង់លទ្ធភាពក្នុងការប្រមូលអនុផលព្រៃឈើ

ជាពិសេសការរកឈើដើម្បីយកមកដុតធ្យូងនឹងធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់សហគមន៍។ ដោយសារក្រុមហ៊ុននៅបន្តវត្តមាននៅក្នុងតំបន់នោះ បានកើតឡើងនូវអសន្តិសុខកម្មសិទ្ធិដីធ្លីយ៉ាងខ្លាំងព្រមទាំងបរិយាសកាសរួមដែលមានការបំភិតបំភ័យ។ នៅពេលដែលសកម្មភាពចិញ្ចឹមជីវិតបច្ចុប្បន្នរបស់ប្រជាជនមិនត្រូវបានគ្រប់គ្រងអោយបានល្អ និងបរិស្ថានកំពុងតែធ្លាក់ចុះនោះ ជាពិសេសពាក់ព័ន្ធនឹងការដុតធ្យូងនៅក្នុងភូមិមួយចំនួនដែលយើងបានទៅដល់ អ្នកភូមិមានបំណងយ៉ាងច្បាស់លាស់ដើម្បីដោះស្រាយបញ្ហានេះតាមរយៈការបង្កើតគំរោងសហគមន៍ព្រៃឈើ (មិនទាន់ត្រូវបានអនុញ្ញាតនៅឡើយទេ ដោយក្រុមហ៊ុន Haining នៅបន្តទាមទារនៅតំបន់នោះ)។ សម្បទានក៏បានធ្វើអោយប៉ះពាល់ដល់ការងារអភិវឌ្ឍន៍របស់អង្គការ Lutheran World Federation ទេ ។

- **ក្រុមហ៊ុន Pheapimex នៅខេត្ត ពោធិសាត់ និង ខេត្តកំពង់ឆ្នាំង**

សម្បទានរបស់ក្រុមហ៊ុន Pheapimex ចំនួន៣១៥.០២៨ហិកតា នៅក្នុងខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំងដែលមានទំហំធំល្វឹងល្វើយ សូម្បីតែតាមស្តង់ដារអន្តរជាតិត្រូវបានផ្តល់ជូននៅឆ្នាំ២០០០ ដោយគ្មានការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងមិនបានបញ្ចប់ EIA ឬ SIA។ គេបានប៉ាន់ស្មានថាមានប្រជាជនជាង ១០០.០០០ នាក់ នៅក្នុងតំបន់សម្បទាន។ ជារួមល្បាយព្រៃរិចរឹល ព្រៃស្រល់ឈើ និងដីដែលមានព្រៃល្បាស់ និងដីកសិកម្មបានចាត់ថ្នាក់ជាប្រភេទដីសំរាប់សម្បទានរបស់ក្រុមហ៊ុន Pheapimex។ សម្បទាននេះមានទីតាំងស្ថិតនៅក្បែរតំបន់ការពារពីរគឺ: តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាបនៅផ្នែកខាងកើត និងដែនជំរកសត្វព្រៃឱរ៉ាល់នៅភាគខាងលិច។ តាមរបាយការណ៍ដំបូងបានអោយដឹងថានឹងមានការសាងសង់រោងចក្រក្រដាសដែលមានការពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងការបំពុលធនធានទឹក ដោយសារធាតុគីមី និងបំណែកឈើដែលជាហេតុបណ្តាលអោយមានកង្វល់ចំពោះទីតាំងដែលនៅក្បែរបឹងទន្លេសាប។

គោលបំណងដំបូងរបស់ក្រុមហ៊ុន Pheapimex ដើម្បីអភិវឌ្ឍន៍សម្បទានរបស់ខ្លួននៅឆ្នាំ២០០០ ត្រូវបានបន្ទុចបង្អាក់ទៅវិញ ដោយការប្រឆាំងពីប្រជាជនមូលដ្ឋាន ដែលក្រោយមកត្រូវបានគាំទ្រដោយអង្គការម្ចាស់ជំនួយ និង NGOs។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៤ ក្រុមហ៊ុន Pheapimex បានផ្តួចផ្តើមសកម្មភាពរបស់ខ្លួនសារជាថ្មីដែលបណ្តាលអោយមានការប្រឆាំងតវ៉ាម្តងទៀតពីសំណាក់អ្នកភូមិ ហើយបានក្លាយជាសោកនាដកម្មមួយ ដោយការបោកគ្រាប់បែកមកលើអ្នកតវ៉ាដែលកំពុងដេកលក់នៅយប់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលបានធ្វើអោយរបួសមនុស្ស៨នាក់ ក្នុងនោះមាន៣នាក់ធ្ងន់ធ្ងរ ក៏ប៉ុន្តែជនប្រព្រឹត្តឧក្រិដ្ឋកម្មមិនទាន់ត្រូវបានចាប់ខ្លួននៅឡើយទេ។ ក្រោយពីព្រឹត្តិការណ៍បោកគ្រាប់បែកនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៤ មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលបានបញ្ជាក់អោយក្រុមហ៊ុនបញ្ឈប់សកម្មភាពរបស់ខ្លួនរហូតដល់មានការសិក្សាអំពីផលប៉ះពាល់លើអ្នកភូមិ និងការធ្វើកសិកម្មរបស់ពួកគេសិន។ ទោះបីជាមានបទបញ្ជានេះក៏ដោយ ក៏ក្រុមហ៊ុនបានបន្តឈូសឆាយដីព្រៃ។ ចុងបញ្ចប់ការបន្តប្រឆាំងពីសហគមន៍មូលដ្ឋានបានធ្វើអោយក្រុមហ៊ុន Pheapimex ត្រូវបានបញ្ឈប់សកម្មភាពរបស់ខ្លួននៅខែមករា ឆ្នាំ២០០៥

បើទោះបីជាការគាំទ្រថ្នាក់ខ្ពស់របស់រដ្ឋាភិបាលមានន័យថា ប្រតិបត្តិការនេះទំនងជានឹងចាប់ផ្តើមម្តងទៀតនៅពេលអនាគតក៏ដោយ។

សហគមន៍ដែលយើងបានទៅដល់ក្នុងកំឡុងពេលស្រាវជ្រាវនៅមូលដ្ឋាន នៅក្នុងតំបន់សម្បទានភាគច្រើនប្រកបរបរចិញ្ចឹមជីវិតរបស់គេដោយការធ្វើស្រូវវស្សា (៨៧%) ដោយមានប្រភពចំណូលបន្ថែម ជាពិសេសមកពីការប្រមូលអនុផលព្រៃឈើ និងសកម្មភាពនេសាទ។ ៦០%ប្រជាជនដែលត្រូវបានធ្វើបទសំភាសន៍យល់ថាចំការបាន ឬនឹងប៉ះពាល់ដល់សកម្មភាពធ្វើកសិកម្មរបស់ពួកគេ ជាពិសេសដោយសារការបាត់បង់ដីធ្លី (៥៧%) ប្រសិនបើដីស្រែរបស់គេមិនត្រូវបានកាត់ចេញពីព្រំប្រទល់សម្បទានទេនោះ។ ចាប់តាំងពីក្រុមហ៊ុនមកដល់មានការធ្លាក់ចុះនូវចំនួនអ្នកភូមិដែលប្រមូលអនុផលព្រៃឈើដោយសារហេតុផលពីរៈ ឆ្នាំការពារមិនអោយចូលទៅតំបន់ព្រៃដែលមានអនុផលព្រៃឈើ និងការធ្លាក់ចុះជារួមនៃភាពសំបូរបែបរបស់អនុផលព្រៃឈើនៅក្នុងតំបន់នោះតែម្តង។ អ្នកភូមិអាចរកចំណូលបានគួរសមដោយពឹងផ្អែកលើភាពសំបូរបែបនៃអនុផលព្រៃឈើតាមរដូវកាល។ ហេតុផលប្រហាក់ប្រហែលគ្នានេះដែរចំពោះអនុផលព្រៃឈើអ្នកភូមិបានលើកឡើងថាមានការធ្លាក់ចុះជារួមនូវធនធានព្រៃឈើ។

ទន្ទឹមនឹងនេះក៏មានរបាយការណ៏អំពីការធ្លាក់ចុះនូវបរិមាណត្រីព្រមគ្នា និងការធ្លាក់ចុះនូវចំនួនអ្នកនេសាទ។ នេះអាចសន្មត់បានថាមកពីសកម្មភាពនេសាទខុសច្បាប់ បើទោះបីជាអ្នកភូមិ ១៤% ដែលត្រូវបានសំភាសន៏បានលើកឡើងថាពួកគេមិនអាចចាប់ត្រីបានទៀតឡើយ ដោយសារក្រុមហ៊ុនបានចាក់បំពេញនូវបឹងបួរដែលជាកន្លែងត្រីរស់នៅអស់ទៅហើយ។ ការបំផ្លាញដល់ធនធានទឹកនេះក៏បានធ្វើអោយប៉ះពាល់ដល់ទឹកសំរាប់គោក្របីផងដែរ។ អ្នកផ្តល់បទសំភាសន៏ ៣នាក់ នៅឃុំអន្សាចំបក់ និង៣នាក់ នៅឃុំអញ្ចាញរូងនិយាយថាសកម្មភាពរបស់ក្រុមហ៊ុនបានផ្លាស់ពណ៌ទឹកពីខៀវទៅជាខ្មៅ។

ការតាំងទីលំនៅដ្ឋានថ្មី និងការបាត់បង់ទ្រព្យសម្បត្តិ (ជាពិសេសដីស្រែ) គឺជាក្តីកង្វល់ដ៏ចំបងមួយសំរាប់អ្នកភូមិជាច្រើន ដែលបានធ្វើបទសំភាសន៏។ ក៏វិតចុងក្រោយនៃការតាំងទីលំនៅជាថ្មី និងការបាត់បង់ទ្រព្យសម្បត្តិរបស់អ្នកភូមិ គឺអាស្រ័យទៅលើការកំណត់ព្រំប្រទល់សម្បទានចុងក្រោយ រដ្ឋាភិបាលបានសំរេចលៃលកដីខ្លះនៅ ក្នុងតំបន់សម្បទានសំរាប់អ្នកភូមិ ប៉ុន្តែមិនទាន់ដឹងពីក៏វិតប៉ុណ្ណានៅឡើយ។

មានគ្រួសារតែមួយប៉ុណ្ណោះក្នុងចំណោមគ្រួសារចំនួន ៧៧ ដែលបានធ្វើបទសំភាសន៏និយាយថាសមាជិកគ្រួសាររបស់គេម្នាក់បានទទួលការងារធ្វើនៅក្នុងចំការ។ កម្មករភាគច្រើននៅក្នុងតំបន់សម្បទានត្រូវបានជួលមកខាងក្រៅ ហើយគេបានលើកឡើងថាលក្ខខណ្ឌការងារតឹងរ៉ឹងយ៉ាងខ្លាំងរួមទាំងការងារច្រើនម៉ោង តំលៃអាហារខ្ពស់ និងជារឿយៗអត្រាកើតជំងឺគ្រុនចាញ់ច្រើន។

ជាទូទៅអ្នកដែលបានសំភាសន៏ចំនួន៨៨% និយាយថាពួកគេមិនសប្បាយរីករាយនឹងការធ្វើចំការនៅទីនេះ ហើយក្រៅពីនោះមិនមានយោបល់អ្វីឡើយ។ គ្មានអ្នកភូមិណាម្នាក់ដែលបានសំភាសន៏សប្បាយចិត្តនឹងការមកដល់របស់ក្រុមហ៊ុនឡើយ។ ការបាត់បង់ព្រៃឈើ និងផលប៉ះពាល់មកលើជីវភាពរបស់ពួកគេស្ទើរតែជាហេតុផល ដ៏

សំខាន់បំផុតនៃការប្ដឹងតវ៉ាចំពោះក្រុមហ៊ុន។ អ្នកភូមិជាច្រើនដែលបានសំភាសន៍និយាយថា ពួកគេចង់អោយក្រុមហ៊ុនឈប់បំផ្លាញព្រៃឈើ និងផ្ដល់ដីកសិកម្មអោយពួកគេវិញ។

- **ក្រុមហ៊ុន Wuzhishan L.S Group នៅខេត្តមណ្ឌលគិរី**

ក្រុមហ៊ុន Wuzhishan ទើបតែត្រូវបានបង្កើតឡើងថ្មីៗនេះកាលពីខែឧសភា ឆ្នាំ២០០៤ ហើយនៅខែកក្កដា ឆ្នាំ២០០៤ បានទទួលការអនុញ្ញាតជាគោលការណ៍ធ្វើចំការដាំដើមស្រល់លើផ្ទៃដីចំនួន ១៩៩.៩៩៩ហិកតា នៅក្នុងស្រុកសែនមនោរម្យ និងសុកអូរាំង នៅខេត្តមណ្ឌលគិរី ដោយមានការអនុញ្ញាតភ្លាមៗលើផ្ទៃដីចំនួន ១០.០០០ហិកតា សំរាប់សាកល្បង និងដាំដុះសំរាប់ពាណិជ្ជកម្ម។ នៅខែមិនា ឆ្នាំ២០០៥ នាយករដ្ឋមន្ត្រីបានសំរេចជាគោលការណ៍សំរាប់តំបន់ដាំឈើគឺកើនដល់៤០០០ហិកតា ដោយត្រូវមានការសំរេចពីក្រសួងកសិកម្មទន្ទឹមនឹងនេះក៏មានផែនការសាងសង់រោងចក្រមួយនៅខេត្តមណ្ឌលគិរីដើម្បីកែប្រែដើមស្រល់ទៅជាជ័រ និងឈើសំរាប់ប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា និងសំរាប់នាំចេញទៅក្រៅប្រទេស។ [៤] ហើយដែនសម្បទានផ្នែកខ្លះក៏ត្រួតស៊ីជាមួយនឹងតំបន់ការពារជីវចំរុះ។

តំបន់នេះគឺជាកន្លែងដែលមានសហគមន៍ជនជាតិភ្នងរស់នៅជាច្រើនព្រមទាំងសហគមន៍ខ្មែរផងដែរ ហើយទីនេះត្រូវបានចាត់ជាប្រភេទភ្នំមានស្មៅដុះយ៉ាងស្រទន់លាយឡំជាមួយព្រៃស្ងួត និងរិចរឹលនៅតាមជ្រលងភ្នំ។ ជនជាតិភ្នងគឺអ្នកសត្តនិយម (ជំនឿថាសព្វសត្វរុក្ខជាតិសុទ្ធតែមានព្រលឹង) ហេតុនេះហើយទើបជំនឿរបស់គេគឺនៅជាប់នឹងទិដ្ឋភាពសណ្ឋានដីដែលមានដីកប់សព និងព្រៃអារក្សផ្ដល់សារៈសំខាន់យ៉ាង ជាពិសេសដល់ពួកគេ។ មាត្រា ២៣-២៨ នៃច្បាប់ភូមិបាលចែងនូវបទប្បញ្ញត្តិ ពិសេសសំរាប់ជនជាតិដើមភាគតិចរួមទាំងការទទួលស្គាល់តាមផ្លូវច្បាប់ទៅលើទស្សនទានទ្រព្យសម្បត្តិសហគមន៍ជនជាតិដើម។

ក្នុងការធ្វើផែនការសម្បទានគ្មានការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានឡើយ និងមានការប្រាស្រ័យទាក់ទងយ៉ាងតឹងតែងជាមួយអាជ្ញាធរមូលដ្ឋាន។ គ្មានការបញ្ចប់ហេតុផលប៉ះពាល់បរិស្ថាន (EIA) និងហេតុផលប៉ះពាល់សង្គម (SIA) ហើយក៏គ្មានផែនទីផ្លូវការផ្សព្វផ្សាយសាធារណៈដែលចង្អុលបង្ហាញអំពីទំហំនៃសម្បទានដែលបានផ្ដល់ជូន។ នៅខែកញ្ញា ឆ្នាំ២០០៤ Wuzhishan បានចាប់ផ្ដើមប្រតិបត្តិការរបស់ខ្លួនយ៉ាងស្វាហាប់ ដោយប្រើប្រាស់ថ្នាំសំលាប់ស្មៅ (glyphosate) ទៅតាមទីវាលស្មៅនៅក្នុងតំបន់សម្បទានរួចដុតចោលស្មៅដែលងាប់ ហើយចាប់ផ្ដើមដាំកូនស្រល់ចំនួន២៥.០០០ដើម។ ក្នុងការរៀបចំដីសំរាប់សម្បទាន Wuzhishan បានឈូសឆាយដីដោយមិនរើសមុខពោលគឺមិនត្រឹមតែវាលស្មៅដែលជនជាតិភ្នងនៅមូលដ្ឋានប្រើប្រាស់សំរាប់ចិញ្ចឹមសត្វពាហនៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងព្រៃព្រលឹង និងផ្នូរដូនតាដែលជាធាតុមួយយ៉ាងសំខាន់នៃវប្បធម៌របស់ជនជាតិភ្នង។ ការប្រើប្រាស់ថ្នាំសំលាប់ស្មៅត្រូវបានសហគមន៍ចោទប្រកាន់ជាទូទៅថាបានធ្វើអោយបំពុលទឹក ប៉ះពាល់សុខភាពមនុស្ស និងបាន

[4] Special Representative of Secretary-General for Human Rights in Cambodia ‘Wuzhishan L.S Group: A pne Plantation in Mondukiri Province’Cambodia Office of the High Commissioner for Human Rights, June 2005.

ទទួលខុសត្រូវចំពោះការងាប់គោ១០ក្បាល បើទោះបីជាអាជ្ញាធរបានអះអាងថាថ្នាំសំលាប់ស្មៅនេះមានសុវត្ថិភាពក៏ដោយ ។

សម្បទាននេះនឹងប៉ះពាល់ដល់៧ឃុំ ក្នុងស្រុក៣ ដែលគេមិនបានដឹងពីព្រំប្រទល់សម្បទានជាក់លាក់ឡើយ រួមទាំងទំហំដែលនឹងត្រូវលែទុកសំរាប់អ្នកភូមិ ។ កង្វះភាពច្បាស់លាស់នៅក្នុងផែនការប្រាកដប្រជាសំរាប់សម្បទាន បាននាំអោយជនជាតិភ្នងចំនួន ៤០០នាក់ សរសេរញ្ញត្តិទៅលោកអភិបាលស្រុកអូរាំង នៅក្នុងខែកញ្ញា ឆ្នាំ២០០៤។ ការប្រឆាំងទ្រង់ទ្រាយធំបានផ្ទុះឡើងនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៥ នៅពេលដែលភាគច្រើនជាជនជាតិភ្នង ដែលរងការប៉ះពាល់ដោយចំការចំនួនពី ៦៥០-៨០០នាក់ បានមកតវ៉ានៅមុខអាគារក្រុមហ៊ុននៅទីរួមស្រុកសែនមនោរម្យដែលនាំអោយសម្តេច **ហ៊ុន សែន** ក្រោយពីប្រជុំគណៈរដ្ឋមន្ត្រីបានចេញសេចក្តីប្រកាសមួយនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ បញ្ជាអោយក្រុមហ៊ុន Wuzhishan ផ្អាកសកម្មភាពរបស់ខ្លួនជាបន្ទាន់នៅក្នុងតំបន់ សម្បទានដែលរំលោភលើដីជនជាតិភ្នង។ គណៈកម្មាធិការអន្តរក្រសួងមួយត្រូវបានបង្កើតឡើងដើម្បីដោះស្រាយ បញ្ហានេះ។ ទោះជាដូច្នេះក៏ដោយនៅចុងខែមិថុនាសហគមន៍ទាំងឡាយបានតវ៉ាអំពីដំណើរគ្មានទៅមុខយ៉ាងច្បាស់ -លាស់ដោយបានបិទផ្លូវនៅក្នុងសម្បទានដែលប៉ះពាល់ដល់ឃុំដែលក្រោយមកត្រូវបានរាយការណ៏ថាបានរងនូវការ គំរាមកំហែង និងបច្ចេកទេសបំភិតបំភ័យជាច្រើន។ ការបិទផ្លូវនេះបានប្រព្រឹត្តទៅអស់រយៈពេលប្រហែលមួយ សប្តាហ៏មុនពេលដែលក្រុមហ៊ុនបានទំលាយដោយប្រើរថយន្តធំផ្ទុកពេញទៅដោយកម្មករកាន់ចប កាំបិត និងដំបង។

ក្នុងដំណើររង់ចាំការយាងមកដល់របស់ព្រះមហាក្សត្រ **នរោត្តម សីហមុនី** ដើម្បីប្រារព្ធរុក្ខទិវាជាតិនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៥ នៅខេត្តមណ្ឌលគីរីបានធ្វើអោយអ្នកភូមិប្រមាណ ២០០នាក់ ដើរសរសៀរតាមកន្លែងបិទផ្លូវរបស់ប៉ូលីស ហើយចូលទៅទីរួមស្រុកសែនមនោរម្យ។ អ្នកភូមិបានមកផ្តុំគ្នានៅក្បែរសាលាខេត្ត ដោយសង្ឃឹមថានឹងបានចូលគាល់ព្រះមហាក្សត្រ។ បន្ទាប់មកនៅថ្ងៃដដែលនោះអ្នកភូមិបានជួបជាមួយ ឯ.ឧ. **នុត សាអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ហើយបានយល់ព្រមចាកចេញពីទីរួមស្រុកសែនមនោរម្យ ជាថ្នូរនឹងការធានាថា គណៈកម្មាធិការខេត្តមួយនឹងត្រូវបង្កើតដើម្បីស្រាវជ្រាវនៅមូលដ្ឋាន ហើយនឹងរាយការណ៏ជូនគណៈកម្មាធិការអន្តរក្រសួងដើម្បីដោះស្រាយជំលោះ។ ទន្ទឹមនឹងនោះក៏មានការឯកភាពថាក្រុមហ៊ុន Wuzhishan គួរបញ្ឈប់ការដាំដើមឈើភ្លាមៗនៅក្នុងឃុំទាំងពីរ។ លើសពីនេះទៅទៀតគណៈកម្មាធិការខេត្តត្រូវទទួលភារកិច្ចស៊ើបអង្កេតការរំលោភដីដែលកើតមានដោយក្រុមហ៊ុន Wuzhishan ទៅលើដីដែលពីមុនត្រូវបានបែងចែកទៅក្រុមហ៊ុន Marubeni Development Corporation ជាក្រុមហ៊ុនជប៉ុនដែលគ្រោងនឹងដាំកៅស៊ូ។

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៥ គណៈកម្មាធិការថ្នាក់ខេត្តបានចាប់ផ្តើមសកម្មភាពរបស់ខ្លួន ដោយបានធ្វើការស្រាវជ្រាវនៅទីតាំងអស់រយៈពេល២ថ្ងៃ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៥ គណៈកម្មាធិការអន្តរក្រសួង នៅក្នុងរបាយការណ៏របស់គណៈកម្មាធិការថ្នាក់ខេត្តបានរកឃើញថាជាសរុបក្រុមហ៊ុន Wuzhishan បានដាំដើមស្រល់លើផ្ទៃដីចំនួន ៨.៩៣៨ហិកតា បានត្រៀមដីចំនួន ៤.២៨៤ហិកតាទៀត និងបានដាំដោយអន្ទើលើផ្ទៃដីចំនួន ៣.២៩៥ហិកតា ហេតុនេះរហូតមកដល់បច្ចុប្បន្នសរុបផ្ទៃដីគឺចំនួន ១៦.៥១៧ហិកតា។ នៅលើផ្ទៃដី ៤.៥០៨ហិកតា

របស់ក្រុមហ៊ុន Marubeni ត្រូវបានដាំដើមស្រល់ដោយក្រុមហ៊ុន Wuzhishan ២.១១១ហិកតា ត្រូវបានដាំដោយអន្លើ និង១.១៦២ហិកតាបានរៀបចំដី ដូចនេះសរុបទាំងអស់ ៧៧៨០ហិកតា។ ហេតុនេះគណៈកម្មាធិការអន្តរក្រសួងបានសំរេចថាក្រុមហ៊ុន Wuzhishan គួរដកចេញពីដីរបស់ក្រុមហ៊ុន Marubeni ។ ពាក់ព័ន្ធនឹងការរំលោភយកដីអ្នកភូមិគណៈកម្មាធិការអន្តរក្រសួងលើកឡើងថាមានការលំបាកក្នុងការចរចា ហើយថានៅពេលនេះទើបតែមានការឯកភាពថាក្រុមហ៊ុនត្រូវតំរូវអោយធ្វើរបងព័ទ្ធជុំវិញសម្បទានរបស់ខ្លួនដើម្បីចៀសវាងការរំលោភយកដី។

Wuzhishan បានចាប់ផ្តើមដាំឈើជាថ្មីម្តងទៀតនៅថ្ងៃទី១៨ ខែសីហា ដោយគ្មានដំណោះស្រាយណាមួយដែលបានចរចាជាមួយសហគមន៍។ នៅពេលសរសេររបាយការណ៍នេះព័ត៌មានចុងក្រោយបានអោយដឹងថា បើទោះបីជាមានសំណើពីឃុំដាក់ដាំ និងសែនមនោរម្យដែលស្នើសុំ១០គម. និងការកាប់ឆ្ការ ៣គម. នៅជុំវិញភូមិកររបស់ពួកគេក៏ដោយ ក៏គេនឹងទទួលបានតែ ៥០០ម. ប៉ុណ្ណោះសំរាប់ការកាប់ឆ្ការនេះ។ ច្បាប់ភូមិបាល ឆ្នាំ២០០១ចែងថាៈ ផ្ទៃដីធំធេងនៅក្នុងដែនសម្បទានអាចអនុញ្ញាតផ្តល់សំរាប់សិទ្ធិសមូលហភាពជនជាតិដើមភាគតិច ប៉ុន្តែជាក់ស្តែងមិនទាន់ត្រូវបានរៀបចំដោយរដ្ឋាភិបាល ឬក្រុមហ៊ុនឡើយ។

ស្ទើរតែគ្រប់គ្រួសារទាំងអស់ដែលបានសំភាសន៍ (៩៨%) ប្រកបរបរកសិកម្ម និងចិញ្ចឹមសត្វជាសំខាន់។ ៦៥% បាននិយាយថាសកម្មភាពរបស់ក្រុមហ៊ុនបានធ្វើអោយប៉ះពាល់ដល់សកម្មភាពកសិកម្មទាំងនេះ ពិសេសគឺបណ្តាលមកពីការបាត់បង់ដីកសិកម្ម និងប៉ះពាល់ពីបាញ់ថ្នាំសំលាប់ស្មៅ glyphosate ។ នៅក្នុងការប្រជុំក្រុមតូចមួយនៅក្នុងឃុំសែនមនោរម្យ គេបានលើកឡើងថានៅពេលនេះស្ត្រីអ្នកភូមិជាច្រើនមិនចេញទៅស្រែទេ ដោយខ្លាចកម្មករក្រុមហ៊ុនចាប់រំលោភ។

ការនេសាទ និងការប្រមូល NTFP គឺជាសកម្មភាពសំខាន់ទីពីរ។ មិនមានការធ្លាក់ចុះច្រើននូវចំនួនអ្នកដែលធ្វើនេសាទឡើយ(៧១%)បើទោះបីជាធនធានត្រីបានធ្លាក់ចុះដែលបណ្តាលមកពីមូលហេតុសំខាន់គឺសកម្មភាពនេសាទខុសច្បាប់ និងភាពរាំងស្ងួតដែលបានកើតឡើងនៅឆ្នាំនេះ។ ក្រៅពីនេះក៏មិនមានការធ្លាក់ចុះនូវចំនួនអ្នកដែលប្រមូលអនុផលព្រៃឈើឡើយ (៨១%)។ ប៉ុន្តែអ្នកផ្តល់បទសំភាសន៍បានរាយការណ៍ពីការធ្លាក់ចុះយ៉ាងច្រើននូវបរិមាណឈើដែលត្រូវបានទំលាក់កំហុសជាសំខាន់ទៅលើក្រុមហ៊ុន Wuzhishan ដែលបានឈូសឆាយព្រៃឈើ។ គេក៏បានកត់សំគាល់ផងដែរថា មានការធ្លាក់ចុះនូវចំនួនសត្វព្រៃដែលបណ្តាលមកពីសកម្មភាពប្រមាញ់របស់មនុស្សជាច្រើនប្រភេទព្រមទាំងការបាត់បង់ជំរកដោយសារសកម្មភាពរបស់ក្រុមហ៊ុន Wuzhishan ។

នៅក្នុងពេលសរសេរនេះគេមិនបានដឹងពីកំរិតពិតប្រាកដនៃការបាត់បង់ទ្រព្យសម្បត្តិរបស់អ្នកភូមិព្រោះព្រំប្រទល់ចំការពិតប្រាកដដែលស្ថិតនៅក្បែរភូមិកំពុងស្ថិតក្នុងភាពចរចានៅឡើយ។ ទោះបីជាដូច្នេះក៏ដោយអ្នកផ្តល់បទសំភាសន៍ចំនួន ៥៧% នឹងបាត់បង់ដីធ្វើស្រែរបស់គេមួយចំនួន។ លើសពីនេះទៅទៀតវាច្បាស់ណាស់ថាវាលស្មៅនៅឆ្ងាយពីភូមិដែលបច្ចុប្បន្ននេះប្រើប្រាស់ដោយអ្នកភូមិសំរាប់ចិញ្ចឹមសត្វពាហណៈកំពុងត្រូវបានបាត់បង់។ ព្រៃឈើធម្មជាតិ និងដើមឈើហូបផ្លែ (ដែលដុះនៅក្នុង ព្រៃ និងនៅលើវាលស្មៅ) កំពុងត្រូវបានកាប់រំលំដែលមាន

សារៈសំខាន់សំរាប់ការប្រមូល NTFP ។ លើសពីនេះទៅទៀត សត្វ ផ្លែឈើ និងកសិផលកំពុងត្រូវបានលួចដោយកម្មករក្រុមហ៊ុន ។

ទីតាំងវប្បធម៌សំខាន់ៗដូចជាព្រៃព្រលឹង និងវាលកប់សពក៏ត្រូវបានបំផ្លាញដែរ ។ ការទទួលស្គាល់តាមផ្លូវច្បាប់ទៅលើកម្មសិទ្ធិដីមានភាពស្មុគ្រស្មាញ ដោយប្រព័ន្ធកម្មសិទ្ធិសមូហភាពដែលត្រូវបានប្រើប្រាស់ដោយជនជាតិដើមភាគតិចដែលមានចែងនៅក្នុងច្បាប់ភូមិបាល (ឆ្នាំ ២០០១) ប៉ុន្តែតំរូវអោយមានអនុក្រឹត្យដោយឡែកមួយទៀតដើម្បីមានប្រសិទ្ធភាព ។ មានបរិយាកាសភ័យខ្លាច និងអសន្តិសុខចំពោះកម្មសិទ្ធិដី ។

ជាសរុបគ្រួសារចំនួន ២១% ដែលបានសំភាសន៍ បាននិយាយថាពួកគេមានសមាជិកគ្រួសាររបស់គេធ្វើការនៅក្នុងចំការ ។ កម្មករម្នាក់ៗធ្វើការ ៨ម៉ោងក្នុងមួយថ្ងៃ និងបានទទួលប្រាក់ខែចន្លោះពី ៣០-៤២.៥ដុល្លា ដោយមានកម្មករមួយចំនួនក៏ទទួលបានអង្ករ ២៥គ.កក្នុងមួយខែផងដែរ ។ UNCOHCHR បានពណ៌នាពីស្ថានភាពការងារនៅក្នុងចំការថាមានការលំបាក ។ អ្នកភូមិដែលបានសំភាសន៍បានបញ្ជាក់ថា : នៅពេលឈឺពួកគេមិនអាចស្នើសុំសំរាកបានទេ ។ ពួកគេមិនបានទទួលប្រាក់ខែពេញលេញ ។ ពួកគេមានការព្រួយបារម្ភអំពីករណីរំលោភក្នុងចំណោមកម្មករ ។ ពួកគេទទួលសំពាធអោយធ្វើការធ្ងន់ធ្ងរ ហើយកម្មករបានលួចចៀម ឆ្កែ និងគោ ក្របី ពីអ្នកភូមិដើម្បីយកទៅបរិភោគ ។ មានរបាយការណ៍ជាច្រើនក្នុងខែសីហាបង្ហាញថាមានកម្មករភាគច្រើនជាអ្នកចំណាកស្រុក ។

សម្បទានរបស់ក្រុមហ៊ុន Wuzhishan បានផ្តល់នូវផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរមកលើអ្នកស្រុកជាពិសេសជីវភាពរបស់ជនជាតិដើមភាគតិចដែលជំរុញអោយមានការតវ៉ាប្រឆាំង និងទាមទារអោយរដ្ឋបាលកណ្តាលមកធ្វើអន្តរាគមន៍នៅក្នុងការចរចារកដំណោះស្រាយ ។ កង្វះខាតទាំងស្រុងនូវការពិគ្រោះយោបល់ ជាមួយប្រជាជននៅមូលដ្ឋានក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ សម្បទានបាននាំអោយមានការមិនជឿទុកចិត្តយ៉ាងខ្លាំងចំពោះក្រុមហ៊ុន និងការយល់ឃើញជាទូទៅថា កង្វល់របស់ប្រជាជនមូលដ្ឋានមិនត្រូវបានដោះស្រាយអោយបានពេញលេញ ។ ទន្ទឹមនឹងនេះមន្ទីរនៅថ្នាក់ខេត្ត និងអាជ្ញាធរមូលដ្ឋានមិនត្រូវបានពិគ្រោះយោបល់ ហើយដាក់នៅខាងក្រៅដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត ។ នៅពេលដែលសាកសួរថាតើអ្នកយល់ឃើញដូចម្តេចចំពោះក្រុមហ៊ុន ៨៨% នៃគ្រួសារដែលបានសំភាសន៍បាននិយាយថា ពួកគេមិនចូលចិត្តក្រុមហ៊ុន និង១១%បាននិយាយថាពួកគេចូលចិត្តក្រុមហ៊ុន ដោយសារថាពួកគេបានទទួលការងារធ្វើ ។ បើទោះបីជាអ្នកភូមិមួយចំនួនចង់អោយក្រុមហ៊ុនចាកចេញក៏ដោយក៏ភាគច្រើនមានបំណងចង់ចរចាអោយក្រុមហ៊ុននៅបន្ត ប្រសិនបើក្រុមហ៊ុនមិនរំលោភលើដីរបស់ពួកគេ ។ ប៉ុន្តែនៅពេលនេះគណៈកម្មាធិការអន្តរក្រសួងបានចាត់ទុកថា អ្នកភូមិបានទាមទារដីច្រើនពេក ហើយមិនទាន់រកដំណោះស្រាយបាននៅឡើយ ។

- **ការប្រើប្រាស់ក្នុងស្រុកនូវដើមអាកាស្យា និង Melaleuca នៅខេត្តព្រៃវែង និងស្វាយរៀង**

ខេត្តព្រៃវែង និងស្វាយរៀងដែលស្ថិតនៅប៉ែកបូព៌ានៃប្រទេសកម្ពុជា គឺជាតំបន់មានសារៈសំខាន់ក្នុងការផលិតស្រូវ បើទោះបីជាទូទៅដីមានគុណភាពមិនសូវល្អហើយតំបន់នេះតែងតែរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួតក៏ដោយ។ តំបន់នេះត្រូវបានចាត់ចូលក្នុងប្រភេទវាលទំនាបទឹកលិចសំរាប់ផលិតស្រូវវស្សាដែលមានព្រៃ និងធនធានធម្មជាតិផ្សេងទៀតតិចតួចប៉ុណ្ណោះ។ នៅក្នុងតំបន់ទាំងនេះអ្នកភូមិដាំដើមអាកាស្យា ប្រេងខ្យល់ និង ដើមស្នាច់ នៅលើដីរិចរឹល ដូចជាតាមភ្លឺស្រែ និងរបងផ្ទះរបស់គេ។ អ្នកភូមិនិយាយថាពួកគេដាំដើមឈើទាំងនេះដោយហេតុថាគ្មានប្រភពឈើផ្សេងទៀតសំរាប់ដុតឬសំរាប់យកមកប្រើការអ្វីផ្សេងទៀតឡើយ ហើយគ្មានប្រភេទឈើណាផ្សេងដែលសក្តិសមសំរាប់តំបន់ដីរិចរឹលទាំងនេះផងដែរ។

ជាសរុបយើងបានចុះទៅអង្កេតទៅលើគ្រួសារចំនួន១០។ ៩0%នៃគ្រួសារដែលបានធ្វើបទសំភាសន៍គឺជាគ្រួសារកសិករ ហើយគ្រួសារភាគច្រើនប្រកបរបរចិញ្ចឹមសត្វ និងសកម្មភាពរកចំណូលបន្ថែមផ្សេងទៀត (គោ ជ្រូក មាន់ ទា)។

ជាទូទៅកសិករអាចរកចំណូលបានត្រឹមតែសំរាប់រស់ដោយមានស្រូវអង្ករសល់ខ្លះយកទៅលក់យកលុយ។ ជារួម ៧៧% នៃចំនួនអ្នកផ្តល់សំភាសន៍ យ៉ាងហោចណាស់បានដាំដើមឈើលូតលាស់លឿនមួយប្រភេទនេះដែរ (អាកាស្យា ប្រេងខ្យល់ ឬ ដើមស្នាច់)។ ចំពោះអ្នកភូមិទាំងអស់ដែលដាំឈើ៦៥%បានដាំឈើចន្លោះពី ១-៥ឆ្នាំ។ ២0%បានដាំចន្លោះពី ៦-១០ឆ្នាំ និងអ្នកឯទៀតបានដាំឈើនេះជាង ១០ឆ្នាំមកហើយ។ នៅពេលសួរថា តើមានការបង្រៀនអោយដាំដើមឈើបែបណាដែរឬអត់នោះ ៩៨% និយាយថា " ទេ "។ បើតាមអ្នកផ្តល់បទសំភាសន៍ខ្លះបានអោយដឹងថា កូនឈើទាំងនោះយកមកពីប្រទេសវៀតណាម។

នៅពេលសួរថាតើដើមឈើនោះប៉ះពាល់ដល់គុណភាពដីដែរឬអត់ នោះ ៤%និយាយថាវាមានប្រយោជន៍សំរាប់ដី ៥១%និយាយថាដើមឈើមិនល្អទេព្រោះធ្វើអោយប៉ះពាល់ដល់គុណភាពដី ១២%និយាយថាដើមឈើមិនប៉ះពាល់ដីទេ ហើយក្រៅពីនោះឆ្លើយថាមិនច្បាស់។ អ្នកភូមិមួយចំនួនបានកត់សំគាល់ថា នៅពេលគេដាំដើមឈើនៅក្បែរត្រពាំងពេលនោះត្រពាំងបែរជាគ្មានត្រី។ អ្នកភូមិដែលមិនបានដាំដើមឈើត្រូវបានសួរថាតើពួកគាត់ចង់អោយអ្នកភូមិផ្សេងទៀតដាំដើមឈើឆាប់ធំដែរឬទេ ៣៨%និយាយថាគ្មានបញ្ហា ១៥%និយាយថាមានបញ្ហា ហើយក្រៅពីនោះឆ្លើយថាមិនច្បាស់។ នៅពេលនេះចំពោះអ្នកដែលមិនបានដាំឈើ ៤៦%មានបំណងដាំឈើទៅអនាគត ៣៨%មិនចង់ ហើយអ្នកដែលនៅសល់ឆ្លើយថាមិនច្បាស់។ ប្រជាជនបាននិយាយថាពួកគេចង់ដាំដើមឈើព្រោះឈើនេះធំលឿនណាស់។ អ្នកខ្លះនិយាយថាមិនចង់ដាំទេព្រោះឈើនេះធ្វើអោយហិលដី។

ស្ថានភាពនៅខេត្តព្រៃវែង និងស្វាយរៀងទោះក្នុងរូបភាពណាក៏ដោយមិនអាចប្រៀបបានដូចជាចំការឯកវប្បកម្មទ្រង់ទ្រាយធំបានឡើយ។ បើទោះបីជាអ្នកភូមិជាច្រើនដែលបានសំភាសន៍បានដាំដើមឈើឆាប់ធំក៏ដោយ តែបើគិតទៅតាមសណ្ឋានដីវិញ ដើមឈើត្រូវបានដាំត្រង់នេះបន្តិចត្រង់នោះបន្តិច ហើយការប្រើប្រាស់ដីជាសំខាន់គឺការផលិតស្រូវ។ ករណីសិក្សាបានបង្ហាញនូវស្ថានភាពមួយដែលក្នុងនោះការប្រើប្រាស់ដើមឈើឆាប់ធំត្រូវបានមើលឃើញថាជាប្រភពដ៏សំខាន់តាមលក្ខខណ្ឌនៃភាពក្រ។ ជាពិសេសដោយហេតុថាអ្នកភូមិគ្រប់គ្រងដីពួកគេអាចសំរេចជ្រើសរើសយកប្រភេទឈើណាមួយមកដាំ ហើយត្រូវធ្វើយ៉ាងណាចំពោះដើមឈើនោះនៅពេលវាធំ។

# សង្ខេប និង សន្និដ្ឋាន

ការស្រាវជ្រាវដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ បានបង្ហាញនូវចំណងទាក់ទងដែលមិនអាចខ្វះបានរវាងសហគមន៍ជនបទកម្ពុជាដែលរងការប៉ះពាល់ដោយសារការអភិវឌ្ឍសម្បទានសេដ្ឋកិច្ចទៅលើដី និងធនធានធម្មជាតិដែលពួកគាត់ពឹងអាស្រ័យ។ នៅបច្ចុប្បន្ននេះគ្មានចំការណាមួយដែលយើងបានទៅដល់ មានដំណើរការត្រឹមត្រូវនោះទេ ប៉ុន្តែកំពុងស្ថិតនៅក្នុងដំណើរការរៀបចំជាចំការ។ អាចនិយាយបានថាការស្រាវជ្រាវនេះបានកត់ត្រាទុកនូវការផ្លាស់ទីកន្លែងបឋមរបស់ប្រជាជន និងជីវភាពរបស់ពួកគាត់ និងការកែប្រែបរិស្ថានដើមនៅជនបទទៅជាបរិស្ថានមួយនៃការធ្វើឯកវប្បកម្មដើមឈើដែលឆាប់ធំ។

**សេចក្តីសន្និដ្ឋានសំខាន់របស់របាយការណ៍មាន :**

- នៅបច្ចុប្បន្ននេះមានផលប៉ះពាល់មកលើបរិស្ថានដែលមិនអាចចៀសបានដែលជាលទ្ធផលនៃការធ្វើចំការ :
    - ការបំផ្លាញនូវព្រៃឈើដ៏ធំធេងព្រមជាមួយនឹងការធ្លាក់ចុះនូវជីវៈចំរុះ ដែលអាចមានផលប៉ះពាល់មកលើមុខងារចរន្តទឹក និងស្ថេរភាពប្រព័ន្ធអេកូឡូស៊ី
    - ការធ្លាក់ចុះនូវបរិមាណសត្វព្រៃ
    - ផលប៉ះពាល់ជាអវិជ្ជមានមកលើធនធានទឹករួមមានការបំពុលដែលបានប្រែក្លាយពណ៌ទឹកនៅតាមដងអូរលទ្ធភាពដែលអាចបំពុល ដោយសារថ្នាំសំលាប់ស្មៅក្នុងករណីសម្បទានរបស់ក្រុមហ៊ុន Wuzhishan និងការចាក់បំពេញបឹងបួរក្នុងករណីសម្បទានរបស់ក្រុមហ៊ុន Pheapimex ។
- ទន្ទឹមនឹងនោះក៏នឹងអាចមានផលប៉ះពាល់លើបរិស្ថាននៅពេលអនាគតៈ
    - ការបន្តបាត់បង់ព្រៃឈើនៅពេលសម្បទានបានអភិវឌ្ឍន៍ពេញលេញ
    - ផលប៉ះពាល់មកលើសមភាពទឹក និងជលសាស្ត្រនៅមូលដ្ឋាននៅពេលដែលដាំដើមឈើលូតលាស់លឿន ចាក់ឬសទៅក្នុងស្រទាប់ដីខាងក្រោម ហើយធ្វើអោយហួតចរន្តទឹក

      ដោយសារវាមានតំរូវការទឹកខ្ពស់ព្រមទាំងកែប្រែនូវស្ថានភាពជលសាស្ត្រនៅមូលដ្ឋាន។
    - ពន្លឿនការរិចរឹលដីជំងឺរុកគួន និងផលប៉ះពាល់ជាអវិជ្ជមានពីការប្រើប្រាស់ថ្នាំសំលាប់សត្វចង្រៃជាប្រចាំ

- ការបំពុលបរិស្ថានដែលបណ្តាលមកពីការអភិវឌ្ឍរោងចក្រសាច់ឈើ និងក្រដាសនៅលើសម្បទានរបស់ក្រុមហ៊ុន Pheapimex និងរោងចក្រកែឆ្នៃនៅលើសម្បទានរបស់ក្រុមហ៊ុន Wuzhishan ។

● ទន្ទឹមនឹងនេះក៏បានកំណត់ផលប៉ះពាល់សង្គមជាច្រើនមកលើសហគន៍ពាក់ព័ន្ធ :

- ការបាត់បង់លទ្ធភាពក្នុងការចូលទៅប្រមូលអនុផលព្រៃឈើ និងធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជីវភាពប្រជាជននៅមូលដ្ឋាន។ មានចំណងទាក់ទងគ្នាយ៉ាងសំខាន់រវាងសហគមន៍ និងធនធានព្រៃឈើនៅមូលដ្ឋានដែលផ្តល់អនុផលព្រៃឈើ និងដែលត្រូវបានប្រមូលសំរាប់ការប្រើប្រាស់ក្នុងគ្រួសារ និងសំរាប់រកចំណូល។ អនុផលព្រៃឈើក៏បង្កើតនូវសំណាញ់សុវត្ថិភាពសង្គមផងដែរ នៅពេលដែលកសិផលមានការធ្លាក់ចុះ។
- ការបាត់បង់ដីកសិកម្មដោយមិនដឹងថាមានកំរិតប៉ុណ្ណា ដោយហេតុគ្មានផែនទីដែលកំណត់ព្រំប្រទល់សម្បទាននិងកំណត់តំបន់ដែលបែងចែកទុកសំរាប់សហគមន៍។ ទន្ទឹមនឹងនេះក៏គ្មានការបញ្ជាក់ច្បាស់លាស់ថា តើប្រជាពលរដ្ឋនឹងទទួលសំណងចំនួនប៉ុន្មាន (ប្រសិនបើមាន)។
- ការបាត់លទ្ធភាពទទួលបានធនធានផ្សេងទៀត រួមមានធនធានទឹក វាលស្មៅចិញ្ចឹមសត្វពាហណៈ និងតំបន់នេសាទ។
- ដោយករណីលើកលែងចំពោះសម្បទានរបស់ក្រុមហ៊ុន Wuzhishan នៅខេត្តមណ្ឌលគីរី ចំការមិនបានផ្តល់ការងារសំរាប់ប្រជាជននៅមូលដ្ឋានឡើយ ផ្ទុយទៅវិញផ្តល់ការងារទៅអោយអ្នកមកពីក្រៅខេត្តទៅវិញ។ លក្ខខណ្ឌការងារមានការលំបាកយ៉ាងខ្លាំង ជាពិសេសក្នុងករណីសម្បទានរបស់ក្រុមហ៊ុន GreenRich មានលក្ខខណ្ឌសែនវេទនា។ ភាពស្របច្បាប់នៃលក្ខខណ្ឌការងារនៅក្នុងតំបន់សម្បទានខ្លះ អាចចោទជាបញ្ហា។
- នៅគ្រប់សម្បទានទាំងអស់លើកលែងតែសម្បទានរបស់ក្រុមហ៊ុន Green Rich ការចូលមកដល់របស់ក្រុមហ៊ុនបាននាំមកជាមួយនូវការគំរាមកំហែង និងការបំភិតបំភ័យចំពោះសហគមន៍មូលដ្ឋានដែលបានប្រឆាំងចំពោះការអភិវឌ្ឍ។
- គ្មានទំនាក់ទំនងល្អរវាងក្រុមហ៊ុន និងសហគន៍/អាជ្ញាធរមូលដ្ឋាន។ ធ្លាប់មាន និងឈានទៅគ្មានការពិគ្រោះយោបល់អ្វីសោះ។ សេចក្តីសំរេចជាច្រើនដែលពាក់ព័ន្ធនឹងសម្បទានត្រូវបានធ្វើឡើងដោយរដ្ឋបាលកណ្តាល ដោយមិនអោយអាជ្ញាធរមូលដ្ឋានមានអំណាចអ្វីសោះ។

● សម្បទានទាំង៤ដែលបានចុះទៅដល់កំពុងរំលោភទៅលើច្បាប់ភូមិបាល ឆ្នាំ ២០០១ ដែលចែងថា លើកលែងតែមានករណីពិសេស សម្បទានមិនត្រូវលើសពីទំហំ ១០.០០០ ហិកតាឡើយ។ កង្វះខាត EIA and SIA នៅក្នុងសម្បទានភាគច្រើនគឺជាក្តីកង្វល់ដ៏ធ្ងន់ធ្ងរ។ កង្វះខាតនៃ EIA and SIA របស់សម្បទានគឺជាក្តីកង្វល់ដ៏ធ្ងន់ធ្ងរ ដូចជាករណីក្រុមហ៊ុន Green Rich (តំបន់ការពារនៃឧទ្យានជាតិបូទុមសាគរ) និង Wuzhishan (Seima Biodiversity Conservation Area) ដែលធ្វើអោយប៉ះពាល់ដល់តំបន់ការពារទាំងនោះ។ បើទោះបីជាពាក្យបណ្តឹងនៅពេលថ្មីៗនេះទៅតុលាការពីករណីក្រុមហ៊ុន Green Rich ដែលបានធ្វើឡើងដោយក្រសួងបរិស្ថានគឺជាជំហានវិជ្ជមានមួយក៏ដោយ។

● ជារួមបទពិសោធន៏របស់សហគមន៏ក្នុងការអភិវឌ្ឍចំការធំៗ នៅកម្ពុជានៅពេលនេះមានលក្ខណៈជាអវិជ្ជមាន និងមានការពាក់ព័ន្ធភាគច្រើនបំផុតជាមួយការបាត់បង់សិទ្ធ និងការបំផ្លាញធនធានធម្មជាតិ និងដីធ្លីដែលសហគមន៏ពឹងអាស្រ័យដោយមានផ្តល់ឱកាសតិចតួចក្នុងការរកបរចិញ្ចឹមជីវិតនៅទីកន្លែងនោះ។

## អនុសាសន៏

ផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា និងកិច្ចខិតខំប្រឹងប្រែងជាច្រើនដែលគួរអោយកត់សំគាល់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជាគួរអោយកោតសរសើរយ៉ាងខ្លាំង។ ប៉ុន្តែការអភិវឌ្ឍសេដ្ឋកិច្ចមានន័យបែបស្ថាបនាតែនៅពេលណាដែលផលប៉ះពាល់សង្គមជាទូទៅមានលក្ខណៈវិជ្ជមាននិងមិនធ្វើអោយប៉ះពាល់ដល់បរិស្ថាននៅកម្ពុជា និងធនធានធម្មជាតិដ៏មានតំលៃ និងសំបូរបែបរបស់ខ្លួន។ នៅពេលបច្ចុប្បន្ននេះយើងនៅមិនទាន់ដឹងច្បាស់ថា តើការធ្វើចំការដាំដើមឈើឆាប់ធំនឹងចូលរួមចំណែកឬក៏បំផ្លាញការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជាហើយលើសពីនេះទៅទៀត យើងក៏មិនទាន់ច្បាស់ថានេះនឹងនាំទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌សំរាប់ប្រជាជនកម្ពុជាទាំងមូលដែរឬអត់។ ប៉ុន្តែគេអាចនិយាយអោយកាន់តែច្បាស់ថា ការអភិវឌ្ឍចំការបានផ្តល់នូវផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរមកលើបរិស្ថានព្រមទាំងកោសិការសង្គម។

របាយការណ៏នេះមិនមែនអះអាងថា ជាការវាយតំលៃបែបសេដ្ឋកិច្ចទៅលើគំរូសម្បទានសេដ្ឋកិច្ចទាំងមូលដែលត្រូវបានអនុម័តយល់ព្រមដោយរាជរដ្ឋាភិបាលនៅពេលនេះនោះទេពោលគឺមានគោលបំណងត្រឹមតែរួមចំណែកដល់ការពិភាក្សាអំពីសម្បទានសេដ្ឋកិច្ចជាជាងការផ្តល់នូវចំលើយដាច់ស្រេចចំពោះសម្បទាន។ តែទោះជាយ៉ាងណាក៏ដោយការចុះស្រាវជ្រាវនៅមូលដ្ឋានបង្ហាញអោយឃើញថា ផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរផ្នែកសង្គម និងបរិស្ថានដែលមានចំណងទាក់ទងនឹងចំការធំៗ ៤ ដែលកំពុងដំណើរការអភិវឌ្ឍនៅពេលបច្ចុប្បន្ននេះ។ ជាការពិតណាស់ចំការប្រហែលអាចជាផ្នែកមួយចាំបាច់នៃគន្លងអភិវឌ្ឍន៏សេដ្ឋកិច្ចជារួមនៅកម្ពុជា ប៉ុន្តែអោយតែការអភិវឌ្ឍនោះធ្វើឡើងប្រកបដោយការទទួលខុសត្រូវផ្នែកបរិស្ថាន និងសង្គម។

អនុសាសន៍ជាទូទៅក្នុងរបាយការណ៍នេះគឺផ្តោតទៅលើផលប៉ះពាល់ជាអវិជ្ជមានផ្នែកបរិស្ថាន និងសង្គម គួរតែត្រូវបានគេយកទៅពិចារណាមុននឹងការសម្រេចចិត្តឱ្យមានសម្បទានសេដ្ឋកិច្ចសំរាប់ទៅថ្ងៃអនាគត ។ លើសពីនេះទៅទៀត របាយការណ៍នេះបានផ្តល់អនុសាសន៍ឱ្យមានការពិភាក្សាអំពីគោលនយោបាយដែលពាក់ព័ន្ធស្តីអំពីសម្បទានសេដ្ឋកិច្ច ថាតើវាគឺជាដំណោះស្រាយដ៏ល្អបំផុតក្នុងការអភិវឌ្ឍដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងផលប្រយោជន៍យ៉ាងធំធេងសម្រាប់ការអភិវឌ្ឍន៍ជនបទ។

### *ទំនាក់ទំនងរវាងសហគមន៍មូលដ្ឋាន ដីធ្លី និងធនធានធម្មជាតិ*

រាជរដ្ឋាភិបាលកម្ពុជាគួរទទួលស្គាល់នូវចំណងទាក់ទងរវាងជីវភាពរបស់សហគមន៍នៅមូលដ្ឋាន និងដីធ្លី និងធនធានធម្មជាតិដែលពួកគាត់ពឹងអាស្រ័យ។ នេះរួមមានដីសំរាប់ធ្វើកសិកម្ម ដីព្រៃ និង NTFP និងធនធានផ្សេងៗទៀតដូចជា ទឹក និងត្រី។ សហគមន៍ដែលនឹងត្រូវផ្លាស់ប្តូរទីលំនៅដោយសាការអភិវឌ្ឍសម្បទានគឺស្ថិតនៅក្នុងចំណោមអ្នកដែលក្រីក្របំផុត និងអ្នកដែលងាយរងគ្រោះបំផុត ហេតុនេះការផ្លាស់ប្តូរជីវភាពរបស់គាត់បន្ទាប់ពីផ្លាស់ទីលំនៅត្រូវចាត់ទុកថាជាក្តីកង្វល់ដ៏ធំបំផុត។ យុទ្ធសាស្រ្តឆ្លាស់សំរាប់ការកាត់បន្ថយភាពក្រីក្ររួមមានដូចជាជួយផ្នែកកសិកម្មគំរោងឥណទានខ្នាតតូច និងការបំបែកមុខរបរគួរត្រូវចាត់ទុកថាជាជំរើសឆ្លាស់ក្រៅគំរូពីសម្បទានសេដ្ឋកិច្ចដើម្បីកាត់បន្ថយភាពក្រីក្រ។

ទន្ទឹមនឹងនេះគួរទទួលស្គាល់ថានៅតាមទីកន្លែងជាច្រើនសហគមន៍មូលដ្ឋានក៏កំពុងបំផ្លាញធនធានធម្មជាតិផងដែរ ហើយនេះក៏ទាមទារអោយមានដំណោះស្រាយ។ ការបណ្តុះបណ្តាលត្រឹមត្រូវអាចបញ្ចៀសនីន្នាការនេះ ទន្ទឹមនឹងការកសាងគំរោងផ្សេងៗ ដូចជាសហគមន៍ព្រៃឈើ ឬសហគមន៍ព្រៃការពារជាដើមផ្តល់អោយសហគមន៍នូវគំនិតនៃភាពជាកម្មសិទ្ធិ និងការប្តេជ្ញាថែរក្សាការពារធនធានធម្មជាតិដែលនឹងធានានូវការធ្វើអាជីវៈកម្មក្នុងរយៈពេលយូរ និងប្រកបដោយនិរន្តរភាព។

### *ការទទួលបានព័ត៌មានជាសាធារណៈ*

មានកង្វះខាតព័តិមានជាសាធារណៈអំពីទិដ្ឋភាពជាច្រើននៃស្ថានភាពបច្ចុប្បន្នរបស់សម្បទានសេដ្ឋកិច្ច ។ ជាពិសេសប្រទេសផ្តល់ជំនួយគួរបន្តស្នើសុំអោយផ្សព្វផ្សាយអំពីសម្បទានជាសាធារណៈនូវព័តិមានពាក់ព័ន្ធ ដែលគេបានធ្វើឡើងកាលពីកិច្ចប្រជុំ CG ចុងក្រោយ។ សំណើដែលនៅសល់ភាគច្រើនមិនត្រូវបានឆ្លើយតប។ ព័តិមានដែលត្រូវផ្សព្វផ្សាយរួមមានៈ ផែនទីព្រំប្រទល់សម្បទាន EIA ការវាយតំលៃវិនិយោគីនដែលរួមមានការផ្សព្វផ្សាយអំពីសាខាក្រុមហ៊ុន[5] កិច្ចសន្យាសម្បទាន និងស្ថានភាពអនុវត្តន៍តាមកិច្ចសន្យា។

[5] ត្រូវប្រកាសអំពីសាខាក្រុមហ៊ុនដើម្បីចៀសវាងការបន្លំចូលមកកម្ពុជា នូវក្រុមហ៊ុនដែលមានកេរ្តិ៍ឈ្មោះមិនល្អ។ ករណីជាក់ស្តែងគឺទំនាក់ទំនងរវាងក្រុមហ៊ុន Green Elite Co. Ltd, និង ក្រុមហ៊ុនសាច់ឈើ និងក្រដាសអាស៊ី ( APP )

### *ដំណើរការផ្តល់សម្បទានសេដ្ឋកិច្ច*

តាមរយៈដំណើរការផ្តល់សម្បទានសេដ្ឋកិច្ចគួរត្រូវបានពិនិត្យពិច័យ និងសើរើឡើងវិញ។ ដំណើរការត្រឹមត្រូវជាបឋមត្រូវពាក់ព័ន្ធជាមួយភ្នាក់ងារមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលគួរកំណត់តំបន់ដែលសមស្របសំរាប់ការអភិវឌ្ឍជាសម្បទានសេដ្ឋកិច្ច និងបន្ទាប់មកត្រូវឆ្លងកាត់ដំណើរការដេញថ្លៃដែលត្រូវធ្វើឡើងដោយចំហរគណនេយ្យភាព និងតម្លាភាព។ ផ្ទុយទៅវិញប្រព័ន្ធបច្ចុប្បន្ននេះហាក់ដូចជាផ្អែកទៅលើកំណត់ទៅលើតំបន់សម្បទានដោយក្រុមហ៊ុនផ្ទាល់តែម្តង ហើយដែលក្រោយមកត្រូវស្នើសុំដោយផ្ទាល់ពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ដំណើរការសំរេចបន្ទាប់មកគ្មានតម្លាភាព និងគ្មានគណនេយ្យភាព។

សហគមន៏គួរត្រូវបានពិគ្រោះយោបល់ *នៅដំណាក់កាលធ្វើផែនការ* មុនពេលផ្តល់សម្បទាន និងគួរចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើផែនការ។ នៅពេលបច្ចុប្បន្ននេះវាច្បាស់ណាស់ថា សហគមន៏ស្ទើរតែគ្មានការចូលរួមសោះនៅក្នុងដំណើរការធ្វើផែនការ។ ដោយហេតុនេះហើយទើបវាមិនទំនងសោះថា សហគមន៏នឹងទទួលផលប្រយោជន៏ផ្នែកសេដ្ឋកិច្ចពីការធ្វើចំការសោះឡើយ។ យ៉ាងហោចណាស់ការចូលរួមគួរមានព័ត៌មានតាមរូបភាពមួយសមរម្យដែលត្រូវបានផ្តល់ជូនសហគមន៏ដែលរងការប៉ះពាល់ និងការរៀបចំវេទិកាសាធារណៈដែលមន្ត្រីមានសមត្ថកិច្ចអាចដោះស្រាយនូវកង្វល់របស់សហគមន៏។ប្រសើរជាងនេះទៅទៀតនោះគឺដំណើរការនៃ "ការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួម"（PLUP）ដែលពាក់ព័ន្ធអោយសហគមន៏កំណត់ការប្រើប្រាស់ដីដោយពួកគេផ្ទាល់រួមទាំងដីដែលអាចប្រើប្រាស់ជាសម្បទានសេដ្ឋកិច្ច។

ក្រុមហ៊ុនធ្វើចំការអាចធ្វើសកម្មភាពតាមរបៀបមួយកាន់តែមានការទទួលខុសត្រូវដែលក្រុមហ៊ុនMarubeni Development Corporation នៅខេត្តមណ្ឌលគីរីអាចជាករណីជាក់ស្តែងមួយ បើទោះបីជានៅមិនទាន់ច្បាស់ថាតើក្រុមហ៊ុន Wuzhishan បានធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរទៅលើដីដែលក្រុមហ៊ុន Marubeni បានទទួលការអនុញ្ញាតអោយអភិវឌ្ឍន៏ដែរឬអត់។ គេយល់ថាក្រុមហ៊ុន Marubeni បានសិក្សាលទ្ធភាពគំរោងដែលពាក់ព័ន្ធនឹងការពិគ្រោះយោបល់ជាមួយសហកមន៏មូលដ្ឋានមុននឹងឈានទៅដល់ការធ្វើការសិក្សា EIA និង SIA។ បើតាមរបាយការណ៏ពីមូលដ្ឋានបានអោយដឹងថា ក្រុមហ៊ុនបានសំដែងនូវការចាប់អារម្មណ៏ក្នុងការអនុវទ៏គំរោងសាកល្បងមួយដោយផ្តល់ប័ណ្ណកម្មសិទ្ធិសហគមន៏ជូនជនជាតិដើមភ្នងដែលរស់នៅក្បែរនោះ។

### *ការរំលោភដីធ្លី*

រាល់សម្បទានទាំងអស់គួរត្រូវកំណត់នៅលើផែនទីដែលអាចរកបានជាសាធារណៈ ហើយគួរបោះបង្គោលអោយបានច្បាស់លាស់មុនពេលចាប់ផ្តើមឈូសឆាយ និងដាំដើមឈើដើម្បីចៀសវាងការរំលោភដោយខុសច្បាប់លើដីសាធារណៈ ឬដីឯកជន។ សហគមន៏ និងអាជ្ញាធរមូលដ្ឋានគួរមានពេលវេលាគ្រប់គ្រាន់ដើម្បីផ្ទៀងផ្ទាត់ព្រំប្រទល់សម្បទាន និងគួរមានយន្តការសំរាប់ដោះស្រាយជំលោះប្រកបដោយតម្លាភាពបើកចំហរសំរាប់សាធារណៈជន និងឆាប់រហ័ស។

### *ការផ្លាស់ប្តូរទីលំនៅ ការបាត់បង់ទ្រព្យសម្បត្តិ និងសំណង*

នៅពេលបច្ចុប្បន្ននេះមានការយល់មិនច្បាស់លាស់ក្នុងចំណោមអ្នកភូមិ ថាតើពួកគេនឹងទទួលបានសំណងចំនួនប៉ុន្មាន ចំពោះដីធ្លីដែលបានបាត់បង់ ឬមួយក៏ពួកគេនឹងទទួលបានដែរឬអត់។ តាមច្បាប់ភូមិបាលឆ្នាំ ២០០១ រាជរដ្ឋាភិបាលបានណែនាំដែលត្រូវអនុវត្តន៏សំរាប់គំរោងអភិវឌ្ឍន៏ផ្លូវការដូចជាគំរោងដែលគាំទ្រដោយ IMF បើទោះបីជានៅមិនទាន់ច្បាស់ថាតើគំរោងទាំងនោះនឹងត្រូវអនុវត្តលើក្រុមហ៊ុនឯកជនដែរឬអត់។ ការផ្តល់សំណងជូនសហគមន៏ដែលត្រូវផ្លាស់ប្តូរទីលំនៅ ឬអ្នកដែលបានបាត់បង់ទ្រព្យសម្បត្តិត្រូវតែមានគ្រប់ចំនួនដើម្បីធានាអោយអ្នកភូមិអាចកសាងជីវិតថ្មីសមរម្យ។ បេសកកម្មដើម្បីការឯកភាពចំពោះលក្ខខណ្ឌផ្លាស់ប្តូរទីលំនៅ និងសំណងជាមួយសហគមន៏មិនគួរធ្វើឡើងក្រោមបរិយាកាសគំរាមកំហែង ឬបំភិតបំភ័យឡើយ ឧទាហរណ៏ការប្រើប្រាស់កំលាំងប្រដាប់អាវុធ ឬកំលាំងប៉ូលីសអមដំណើរទៅជាមួយ។

### *ការងារ*

ប្រសិនបើមានផលប្រយោជន៏ចំពោះប្រជាជនមូលដ្ឋានពីការទទួលបានការងារពេលដំបូងនៃគំរោងចំការ - ឈើដាំនោះគួរផ្តល់ការងារជូនប្រជាជនមូលដ្ឋានអោយធ្វើការនៅក្នុងចំការ។ ក្រោយពីដំណាក់កាលនៃការកសាងចំការពេលដំបូងនៅពេលដែលឱកាសការងារនៅក្នុងចំការបានធ្លាក់ចុះគួរកសាងយុទ្ធសាស្រ្តដើម្បីការងារ /មុខរបរឆ្លាស់ដើម្បីទ្រទ្រង់គ្រួសារដែលមិនអាចមានការងារទៀងទាត់នៅក្នុងចំការ។

លក្ខខណ្ឌការងារនៅក្នុងចំការមានការលំបាក និងគ្រោះថ្នាក់ហើយភាគច្រើនស្ថិតនៅក្នុងព្រៃជ្រៅតំបន់កើតជំងឺគ្រុនចាញ់ដែលនៅទីនោះមណ្ឌលសុខភាពហើយសូម្បីតែទីផ្សារក៏មានកំរិតយ៉ាងខ្លាំង។ ប៉ុន្តែនេះមិនបានអនុវត្តន៏ច្បាប់ការងាររបស់កម្ពុជាសំរាប់ក្រុមហ៊ុនឡើយ ហើយដែលត្រូវតែអនុវត្តន៏ព្រោះជាលក្ខខណ្ឌលំបាក។

### *គណនេយ្យភាពរបស់ក្រុមហ៊ុន*

ក្រុមហ៊ុនទាំងអស់ត្រូវទទួលខុសត្រូវផ្នែកបរិស្ថាន និងសង្គមដែលមានចែងនៅក្នុងកិច្ចសន្យា (ប៉ុន្តែនៅពេលនេះកិច្ចសន្យាមិនសូវផ្សព្វផ្សាយសាធារណៈឡើយ)។ ជាពិសេសតាមគំរូក្រុមហ៊ុន Green Rich ក្រុមហ៊ុនទាំងអស់គួរតែដាក់ទណ្ឌកម្មអោយធ្ងន់ធ្ងរ ប្រសិនបើគេរំលោភទៅលើលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យារបស់គេ។ ក្រៅពីលក្ខខណ្ឌព្រមព្រៀងនៅក្នុងកិច្ចសន្យាវិធានការជាក់លាក់ត្រូវធ្វើឡើងដើម្បីធានាថា ក្រុមហ៊ុនទាំងអស់ផ្តល់ផលប្រយោជន៏ដល់សហគមន៏មូលដ្ឋានមិនត្រឹមតែលក្ខខណ្ឌសំរាប់ការងារដែលត្រូវស្ថិតនៅក្រោមរូបភាពនៃការធានាខ្លះ ប៉ុន្តែរួមទាំងហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្ត និងសង្គមដែលតែងតែត្រូវបានសន្យាចំពោះសហគមន៏មុនពេលគំរោងចាប់ផ្តើម ប៉ុន្តែមិនដែលធ្វើតាមការសន្យានោះទេ។

### *ច្បាប់*

ក្នុងក្រិតអប្បបរមាសម្បទានសេដ្ឋកិច្ចទាំងអស់ត្រូវធ្វើឡើងនៅក្នុងព្រំដែននៃច្បាប់កម្ពុជារួមមានច្បាប់ភូមិ-បាល ឆ្នាំ២០០១ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ និងអនុក្រឹត្យពាក់ព័ន្ធដែលត្រូវបានអនុម័ត។ នេះរួមមាន :

- សម្បទានសេដ្ឋកិច្ចគួរផ្តល់អោយតែលើដីដែលជា private property of the state
- សម្បទានសេដ្ឋកិច្ចគួរតែមិនប៉ះពាល់ដល់ private ownership or collective ownership របស់សហគមន៍
- សម្បទានសេដ្ឋកិចមិនគួរបង្កើតឡើងនៅកន្លែងដីដែលអាចសំរាប់សមូលហភាព នៅមុនពេលច្បាប់សមស្របផ្សេងៗមាន និងការធ្វើអង្កេតពីការចុះបញ្ជីដីធីត្រូវបានគេធ្វើឡើង
- ដីសហគមន៍គួរទុកបំរុងសំរាប់កំនើនប្រជាជនរយះពេលវែង នៅក្នុងដែនសម្បទានសេដ្ឋកិច្ចដែលស្នើសុំ
- ការដាក់ស្នើសុំនិងការអនុម័តយល់ព្រមដោយក្រសួងមានសមត្ថកិច្ចនូវការវាយតំលៃ ហេតុផលប៉ះពាល់បរិស្ថានមុនពេលសម្បទានសេដ្ឋកិច្ចណាមួយចាប់ផ្តើមសកម្មភាពរបស់ខ្លួន។ លើសពីនេះទៅទៀត EIA គួរផ្តល់ជូនសង្គមស៊ីវិល និងជាពិសេសសហគមន៍ដែលរងផលប៉ះពាល់ផ្ទាល់ដើម្បីអាចអោយមានការចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការអុម័តយល់ព្រម។
- កិច្ចសន្យាសម្បទានគួរចុះហត្ថលេខា និងចុះឈ្មោះនៅក្រសួងដែនដីនគររូបនីយកម្ម និងសំណង់មុនពេលប្រតិបត្តិការណ៍
- តំបន់សម្បទានសេដ្ឋកិច្ចមិនគួរមានទំហំលើសពី ១០.០០០ហិកតា
- សម្បទានសេដ្ឋកិច មិនគួរបង្កើតឡើងនៅក្នុងតំបន់ការពារ
- ផលប្រយោជន៍ដល់សហគមន៍គួរត្រូវបានធានាដោយសម្បទានសេដ្ឋកិច្ច

អនុសាសន៍ជាច្រើននៅក្នុងរបាយការណ៏នេះ គឺមាននៅក្នុងច្បាប់កម្ពុជាតែអ្វីដែលចង់សង្កត់ធ្ងន់នោះគឺការអនុវត្តន៍ច្បាប់ផ្សេងៗគួរមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនគួរតែគោរពតាមច្បាប់។